P-2 - Février 1954 - Tassaneavadey - Mittsalabaley R. le 12-5-54. A (91)
CS-3-4
1955
CHINE FRANÇAISE RÉGIE DU DÉPÔT LÉGAL

ឆ្នាំទី ៤(១)

លេខ ១២

ថ្ងៃទី ១

ខែ កុម្ភៈ

# ទស្សនាវដ្ដី

# មិត្តសាលាបាលី

ផ្សាយចេញ

សាសនា, អក្សរសាស្ត្រ, ប្រវត្តិសាស្ត្រ

ព.ស. ២៤៩៦

ចេញរាល់ថ្ងៃទី១ខែ

ប្រក្រតិទិនសុរិយគតិ

គ.ស. ១៩៥៤



ទីចាត់ការនៅវត្តលង្កា

សង្កាត់លេខ ៦ ក្រុងភ្នំពេញ

មិត្តដែលបានអានទស្សនាវដ្ដីនេះចាត់ទុកជាបានជួយលើកដំកើង

សាសនា អក្សរសាស្ត្រ ទំនៀមទម្លាប់ ព្រះមហាក្សត្រ របស់ខ្លួន

បណ្ណាគារ ហ្នួន-ហៀម

ឧ 40 ឧ

១ ក្នុងសៀវភៅលេខ ១ ប្រចាំខែមករា ដាក់ថា ឆ្នាំទី ៣ នេះជាពាក្យភាន់ច្រឡំ សូមកែជាឆ្នាំទី ៤ វិញ

# មាតិការឿង


| | | |
|---|---|---|
| បណ្ណាធិការ ហួត-ហៀម ..........វិចារណកថា | ទំព័រ | ២ |
| ព្រះឧបាលិវង្ស សូរ-យាយ ..........សីលធម៌ | " | ៣ |
| មហា ប.ស. ..........ដំណើរសម្ដេចព្រះមហាសុមេធាធិបតី | " | ៧ |
| សមាគមមិត្តសាលាបាលី ..........សេចក្ដីថ្លែងការណ៍ | " | ៩ |
| ក៉យ-ប៊ុក ..........អក្សរសាស្ត្រខ្មែរ | " | ១៥ |
| មហាឆាន់ ..........ជាតិមានអ្វីជាកំឡាំង | " | ១៧ |
| ក៉យ-ប៊ុក ..........ចៅស្នែងទស្សក្រយធ្វើដំណើរតែខ្លួនពិភពលោកជាលើកដំបូង | " | ២១ |
| មហាសម-ម៉ន ..........ពតិមានគួរដឹងខ្លះ គួរគិតខ្លះ | " | ២២ |
| ញូង-សៀង ..........អ្នកថួសបង្កើះនឹងគ្រូដេញខ្មោច | " | ២៥ |
| ក៉យ-ប៊ុក ..........រឿងតុក្កតាបនាទធិជាតិ | " | ២៧ |
| ព្រះមហា ប៉ាង-ខាត់ ..........បញ្ចតន្ត្រៈ | " | ៣០ |
| បណ្ណាធិការ ហួត-ហៀម ..........ប្រវត្តិនៃក្មេងកំព្រា | " | ៣២ |


## ដំឡៃជាវ

| ក្នុងប្រទេស | | | ក្រៅប្រទេស | | |
|---|---|---|---|---|---|
| ៦ខែ | ១ឆ្នាំ | ១ក្បាល | ៦ខែ | ១ឆ្នាំ | ១ក្បាល |
| ៤៥រ.០០ | ៩០រ.០០ | ៩រ.០០ | ៥៥រ.០០ | ១០៥រ.០០ | ១០រ.០០ |


អ្នកទទួលឲ្យជាវ

សូមផ្ញើចំពោះទៅលោកម៉ៅ-មី ធ្វើការនៅក្រសួងមហាផ្ទៃ ក្រុងភ្នំពេញ ។

**adresse :** *Monsieur* **Mao-Mey** *Ministère de l'intérieur P. Penh*


សូមអស់លោក អក័យ សាសនាប្រទេសជប៉ុន គណៈកម្មការកែប្រែពុំទាន់ ។

P.K - 27
1954 - 2




គណៈកម្មការទស្សនាវដ្ដីមិត្តសាលាបាលី

| | | | | | |
|---|---|---|---|---|---|
| លោក | ហួត-ហៀម | ប្រធាន | លោក | សម៉ន | សមាជិក |
| " | ម៉ម-ម៉ែម | អនុប្រធាន | " | ឆាន់ | " |
| " | ប៉ៅ-ម៉ី | ហេរញ្ញិក | លោក | ញ៉ូន-សៀន | " |
| ព្រះ ខត្តរាលិវង្ស | សួរ-ហាយ | សមាជិក | " | ចាប-ពិន | " |
| ព្រះ ទេពសត្ថា | គឹម-គួ | " | " | ឌី-ផុន | " |
| ព្រះ មហា | នុត-ព៉ា | " | " | អ៊ុក-ផន់ | " |
| " | ងួត-ទឹម | " | " | ប៊ិន-ហាក | , |

## ព្រះពុទ្ធសាសនា ជាសាសនា សាន្តលោក

មានជនបំពួកខ្លះនិយាយថា "ព្រះពុទ្ធសាសនា ជាសាសនាធ្វើមនុស្សឲ្យល្ងង់ ឲ្យខ្ជិល ឲ្យខ្លាចគេ" តើជាពិតមែនឬ?

តាមសេចក្ដីពិត មិនមែនដូចពាក្យអ្នកថានោះទេ, អ្នកថានោះប្រហែលជាឋិតនៅក្រៅព្រះពុទ្ធសាសនាឬជាអ្នកស្អប់ខ្ពើមពុទ្ធសាសន៍ ទាំងជាអ្នកពុំបានសិក្សាផ្លូវព្រះពុទ្ធសាសនា ដោយហ្មត់ចត់ផងៗ

ឯព្រះពុទ្ធសាសនា បើនិយាយតាមផ្លូវធម៌ ជាសាសនាមានទុជារសតែមួយ គឺ សេចក្ដីសុខក្នុងព្រះនិព្វាន, បើនិយាយ តាមផ្លូវលោក គឺសន្តិភាព ។ ច្បាប់អាណាចក្រសម្រាប់ប្រទេសទាំងឡាយ ដំបូងឡើយសុទ្ធតែផ្ដិតចម្លងយកពីអារ្យធម៌នៃសាសនចក្រ គឺសាសនា, តែដល់អាណាចក្រមានកម្លាំងគ្រប់គ្រាន់ឡើង គេបំបិទនូវគុណានុភាព នៃសាសនចក្រអស់ ព្រោះហេតុនេះ បានជាសន្តិភាពដែលមហាប្រទេសទាំងឡាយស្វែងរកសព្វថ្ងៃ មិនងាយនឹងបានផលជាក់ស្ដែង ទាំងមិនសូវស្របយោបល់គ្នាផង ព្រោះតែគេលះបង់ផ្លូវសាសនចក្រមិនដើរតាមផ្លូវនេះ ឬមិនយកផ្លូវនេះមកជាមេគំនិតសោះ បានជាសន្តិភាពដែលគេត្រូវការនោះ មិនងាយនឹងសម្រេចតាមបំណង ។

តាំងពីផុតសង្គ្រាមៈលោកលើកទីពីរមក ប្រទេសមហាអំណាចទាំងឡាយ សុទ្ធតែអំពាវនាវថាចង់សាងសន្តិភាពឲ្យសាកលលោក, ប៉ុន្តែគ្រប់ជាឃើញតែចំប្រណាំងគ្នាកសាងអាវុធទៅវិញ. កាលបើប្រទេសណាមួយកសាងអាវុធចំរើនថ្មីបែបណាមួយបានហើយ គេតែងតែផ្សាយបង្អួតដាក់ប្រទេសជាបច្ចាមិត្ត;ចំណែកប្រទេសដែលត្រូវគេអួតដាក់នោះ នៅស្ងៀមពុំបានក៏រិះរកមធ្យោបាយណាមួយ ដើម្បីបង្កើតអាវុធពិសេសមួយផ្សេងឲ្យមានអានុភាពជាងអាវុធដែលគេបង្អួតដាក់ខ្លួននោះទៅទៀត ។

វត្ថុអ្វីដែលអ្នកប្រាជ្ញយុទ្ធសាស្ត្របានបង្កើតឡើងហើយ,វត្ថុនោះគេចាត់ថាជារបស់ស័ក្ដិសិទ្ធិអាចសម្រេចផលបានក្នុងពេលដែលប្រើការ ម្ល៉ោះហើយការពិគ្រោះពិភាក្សារកសន្តិភាព របស់ប្រទេសដែលមានវត្ថុស័ក្ដិសិទ្ធិបែបនោះ ធ្វើម្ដេចនឹងស្របយោបល់គ្នា បើអាងវត្ថុស័ក្ដិសិទ្ធិសម្រាប់ប្រទេសតែរៀងខ្លួន, ចំណែកប្រទេសតូចៗ ក៏ព្រួតគ្នាដើរតាមក្រោយសេចក្ដីដឹកនាំនៃមហាប្រទេសណាមួយដែលខ្លួនពេញចិត្ត ។ ម្ល៉ោះហើយ ដំណើរដែលសេរីពិភពលោកត្រូវការសន្តិភាពក៏ក្លាយទៅជាដំណើរប្រណាំងប្រជែងអាវុធគ្នាទៅវិញ ។

គួរឲ្យឆ្ងល់ណាស់ បើសេរីភាពលោកចង់បានសន្តិភាព ម្ដេចក៏ទៅជាអួតអាវុធដាក់គ្នាទៅវិញ ឬ មតិសេរីភាពលោក យល់ថាអាវុធអាចបង្កើតសន្តិភាពបាន? មតិពុទ្ធសាសនាយល់ថា "ការដែលយកអាវុធទៅប្ដូរយកសន្តិភាពនោះ ដាច់ខាតជាពុំបានឡើយ" លុះតែយក អលោភៈ អទោសៈ អមោហៈ ទៅប្ដូរ ទើបបានជាប្រាកដ ព្រោះ លោភៈ ទោសៈ មោហៈ ជាអកុសលមូល ហើយជាគល់នៃអកុសលធម៌ទាំងពួងដែលលោកចាត់ទុកជាមេសង្គ្រាមទាំងពួង លុះតែបន្ថយកម្លាំងអកុសលធម៌ទាំងបីនេះ ទើបបន្ថយកម្លាំងសង្គ្រាមទាំងនោះបាន ។ បើប្រទេសសេរីទាំងឡាយនៅតែខំបំប៉នអកុសលធម៌ទាំងបីនេះ ឲ្យធាត់ធំឡើង សង្គ្រាមលោកនឹងមិនចប់ត្រឹមលើកទីពីរឡើយ ។

លទ្ធិព្រះពុទ្ធសាសនាត្រូវការសន្តិភាពណាស់ ដោយព្រះសម្ពុទ្ធជាម្ចាស់នៃលទ្ធិនេះទ្រង់យល់ថា "សុខដទៃក្រៅពីសន្តិភាព (សេចក្ដីស្ងប់) ពុំមានឡើយ" (នត្ថិ សន្តិបរំ សុខំ, ធ.ខុ.), ហើយទ្រង់យល់ឃើញថា "ក្រៅពីការបន្ថយឥទ្ធិពលនៃអកុសលមូលទាំងបីគ្មានអ្វីអាចញ៉ាំងសន្តិភាពឲ្យកើតឡើងបានទេ"; ព្រោះហេតុនេះ បានជាទ្រង់ប្រដៅសត្វលោកឲ្យខំលះបង់អកុសលមូលទាំងបីឲ្យអស់ស្រឡះពីខន្ធសន្ដាន បើលះមិនបានអស់រលីង ក៏ទ្រង់ឲ្យខំអត់សង្កត់ដូចយកថ្មសង្កត់ស្មៅ ដើម្បីឲ្យបានសន្តិភាពពិតប្រាកដ ។

បណ្ណាធិការ ហួត-ហៀម

# សីលធម៌

(តពីលេខ ១ មក)

គុណសម្បត្តិ ៧ ប្រការនេះជាសីលធម៌របស់គ្រូអាចារ្យ, ចំណែកខាងកូនសិស្សក៏ត្រូវមានសីលធម៌ គឺមានការគោរពបូជា កោតក្រែងសំដែងសេចក្ដីស្មោះត្រង់ដឹងគុណតបគុណចំពោះគ្រូអាចារ្យ តាមភាពនៃខ្លួនជាសិស្ស មិនត្រូវទុកដាក់គ្រូអាចារ្យក្នុងទីដូចជាមិត្តភក្ដិ ស្និទ្ធស្នាលហួសពេកទាល់តែគ្មានសេចក្ដីគោរពកោតក្រែងចំពោះគ្រូអាចារ្យនោះឡើយ ។

សក្ដិធម៌របស់គ្រូអាចារ្យនឹងសិស្សនេះសឹងមានមកក្នុង សិង្គាលោវាទសូត្រដែលពុទ្ធបរិស័ទធ្លាប់បានដឹងហើយកុំបាច់សំដែងក្នុងទីនេះឡើយ ។ ធម៌នេះឯងដែលរាប់ថាជាសីលធម៌ សម្រាប់គ្រូអាចារ្យនឹងសិស្ស ដែលនាំឲ្យទុកចិត្តស្មើចិត្តគ្នាដោយទៀងត្រង់ឥតលាក់លៀម ។

## ៤. សីលធម៌សម្រាប់មាតាបិតា

## ស្វាមីភរិយានិងបុត្រធីតា

សីលធម៌នេះក៏មានក្នុងសិង្គាលោវាទសូត្រនោះដែរ ជាធម៌ដែលមាតាបិតាត្រូវប្រតិបត្តិឲ្យសមគួរដល់បុត្រ-ធីតា, ចំណែកខាងបុត្រធីតាក៏ត្រូវប្រតិបត្តិដោយប្រពៃចំពោះមាតាបិតាវិញ ។ មាតាបិតានិងបុត្រធីតាដែលនៅក្នុងផ្ទះជាមួយគ្នា ; បុត្រធីតាគឺកូនប្រុសស្រីត្រូវប្រតិបត្តិដូច្នេះគឺ

១) មិនត្រូវទទួលទានដំណេកលើគ្រែរចិត្រមានពុកខ្ពស់ប្រសើរជាងមាតាបិតា, ត្រូវប្រើអាសនៈឲ្យថោកថយជាងមាតាបិតា ;

២) មិនត្រូវអង្គុយសំយុងជើងលើកៅអីជិតមាតាបិតាដែលនៅក្នុងទីទាប ;

៣) មិនត្រូវឲ្យសំពត់អាវចាស់ៗ ដែលខ្លួនប្រើប្រាស់ហើយនោះដល់មាតាបិតា ;

៤) មិនត្រូវឲ្យភោជនដែលសល់អំពីខ្លួនបរិភោគដល់មាតាបិតា ។ នេះជាសីលធម៌របស់បុត្រធីតា ដែលត្រូវប្រតិបត្តិចំពោះមាតាបិតា ដោយសង្ខេបប៉ុណ្ណេះ ។

ស្វាមីភរិយាក៏ត្រូវមានចំពោះគ្នាទៅវិញទៅមក ទើបតាំងនៅជាសុខសាមគ្គីជាមួយគ្នាបាន ។ ធម៌នេះក៏មានក្នុងសិង្គាលោវាទសូត្រនោះសព្វគ្រប់ហើយ, សូមមើលក្នុងសៀវភៅសិង្គាលោវាទសូត្រនោះចុះ ។

## ៥. សីលធម៌សម្រាប់ម្ចាស់ផ្ទះនិងភ្ញៀវ

ជនអ្នកម្ចាស់ផ្ទះឬម្ចាស់ទឹកដីខ្លះ តែងមានការប្រស្រ័យដោយករណីយកិច្ចណាមួយមិនទាន់ចំពោះអាគន្តុកៈ គឺភ្ញៀវដែលមករកអ្នកម្ចាស់ផ្ទះឬម្ចាស់ទីលំនៅ, កាលបើខ្វះសីលធម៌ដោយការមិនទទួលភ្ញៀវដែលមកដល់ឲ្យគួរសមតាមឋានៈរបស់ភ្ញៀវទេ នឹងធ្លាក់ទៅជាទោសមួយ ដែលនាំឲ្យគេរាងចាលលែងទៅមករកទៀត តាំងជាហេតុឲ្យដាច់ឬឃ្លាតចាកមេត្រីភាពក្នុងរវាងញាតិមិត្រ, ជួនកាលមិនមែនតែប៉ុណ្ណោះ ថែមទាំងជាហេតុឲ្យភ្ញៀវមានគំនុំគុំគួន បៀតបៀនអ្នកម្ចាស់ផ្ទះនោះតទៅទៀតក៏មាន ។ នេះឯងជាទោសយ៉ាងធំរបស់អ្នកម្ចាស់ផ្ទះដែលមិនឈ្លាសវៃក្នុងសីលធម៌គឺការទទួលរាប់រកបូជាចំពោះភ្ញៀវតាមសមគួរ ។

ដូចជូជកព្រាហ្មណ៍ជាស្រមស្រូមដែលហួសហេតុហ៊ានដើរស្វះស្វែងកាត់ភ្នំកាត់ព្រៃ ចូលរកព្រះវេស្សន្តរពោធិសត្វ ដើម្បីទូលសូមព្រះរាជទ្រព្យសំខាន់ពីរអង្គគឺព្រះរាជកុមារជាលី នឹងព្រះរាជធីតាកណ្ហាជិនា ។ លុះជូជកបានទៅដល់អាស្រមវេស្សន្តរព្រះពោធិសត្វឯព្រៃភ្នំគិរីវង្កត, សំដែងអាការទ្រគោះទ្រើសឃ្លងឥតមានសីលធម៌សមគួរដល់ព្រះពោធិសត្វអ្នកម្ចាស់ទឹកដីនោះ ប៉ុន្តែព្រះពោធិសត្វតែងធ្វើបដិសន្ថារៈដ៏សមគួរចំពោះជូជក, បានអញ្ជើញឲ្យអង្គុយក្នុងអាស្រម, បានឲ្យផ្លែឈើ, បានឲ្យទឹកដល់ជូជកបរិភោគ ។ នេះឯងជាទិដ្ឋានុគតិមួយដ៏ប្រសើរ ។

ការធ្វើបដិសន្ថារៈឲ្យសមល្មមដល់ភ្ញៀវគ្រប់ឋានៈ គឺទាំងជាន់ទាប, ជាន់កណ្ដាល, ជាន់ខ្ពស់ សម្រាប់អ្នកម្ចាស់ផ្ទះ ម្ចាស់ទឹកដី ដូច្នេះឈ្មោះថាសីលធម៌ដ៏ប្រពៃ ។

ភ្ញៀវជាបព្វជិតក្ដី គ្រហស្ថក្ដី មិនរើសថាអ្នកមានយសស័ក្ដិធំ-តូច ឬឥតយសស័ក្ដិទេ ដែលត្រូវការចូលទៅរកផ្ទះឬទឹកដីរបស់គេក៏ត្រូវគោរពអ្នកម្ចាស់ផ្ទះឬម្ចាស់ទឹកដីជាមុន ។ បុគ្គលនេះហៅថាមានសីលធម៌សម្រាប់ខ្លួនជាភ្ញៀវដោយចរិយាបែបបទល្អ-

នោះ គឺបុគ្គលជាភ្ញៀវ ត្រូវតែគោរពចំពោះអ្នកម្ចាស់ទីកន្លែងមុនជាដំបូង មិនត្រូវសំដែងអាការគួរគាយគាន់ ឬកពាហ្វូសហោត នោះទេ, ត្រូវកាលដែលចូលទៅដល់ជិតផ្ទះឬទីកន្លែងអ្នកដទៃ មិនត្រូវប្រញាប់រលះរលាំងចូលទៅភ្លាមៗ ទេ, ត្រូវតែបង្អង់បន្តិចហើយគួរបើត្រូវដោះស្បែកជើង, ដោះមួក ឬដាក់ឆត្រក៏គួរដោះដម្ងោះចេញហើយ ចូលទៅដោយកិរិយាជំនីកម្មឲ្យស្រស់បស់គោរពដោយការឱបដៃ ឬសំពះតាមសណ្ដាប់របស់ប្រទេស ។

បញ្ជូនតបុគ្គលគ្រហស្ថជាភ្ញៀវ, កាលបើបានជួបប្រាស្រ័យចំពោះអ្នកម្ចាស់ផ្ទះឬម្ចាស់ទីកន្លែងណាមួយ ក៏ត្រូវធ្វើបរិយាឲ្យសមរម្យគួរតបរិយាបថ, មិនត្រូវទាក់ស្ដោះកន្លែងមិនគួរ, មិនត្រូវធ្វើឲ្យគេរំខានចិត្ត, មិនត្រូវធ្វើឲ្យប្រឡាក់ទីកន្លែង, មិនត្រូវនិយាយឲ្យឮសំឡេងខ្លាំង ៗ ដែលនាំឲ្យគេធុញទ្រាន់ចិត្តប៉ុណ្ណោះជាដើម; លុះរៀបដំណើរនឹងត្រឡប់មកវិញ ក៏ត្រូវលាអ្នកម្ចាស់ទីកន្លែងដែលមាននៅនោះជាដំបូង ។

ការប្រព្រឹត្តធ្វើខ្លួនឲ្យមានសេចក្ដីគោរពទេយកទ តាំងអំពីពេលដែលចូលទៅរកផ្ទះឬទីកន្លែងអ្នកឯទៀត ដោយការសំដែងខ្លួនឲ្យសុភាពរាបសាព្រមទាំងស្គាល់អាការ, ស្គាល់ពេលវេលារបស់គេផ្ទះនោះហៅថាជាសីលធម៌របស់ភ្ញៀវ ឬឈ្មោះថាជាភ្ញៀវតែងមានសីលធម៌ដ៏ប្រសើរ ។

## ៦. សីលធម៌សម្រាប់ទីប្រជុំ

ទីសំណាក់ការរបស់សមាគម, ទីកន្លែងសំដែងធម៌ ស្ដាប់ធម៌ទេសនា, ទីកន្លែងសន្និសីទ, ទីកន្លែងបង្រៀនឬទីណាមួយក្រៅពីនេះសុទ្ធតែគួរហៅថា "ទីប្រជុំ" បានទាំងអស់ ។ ការនិមន្តនអញ្ជើញដោយលិខិតលាយលក្ខណ៍អក្សរក្ដី, ការប្រាប់គ្នាតៗ ក្ដី, ការនិយាយណាត់សន្យាគ្នាក្ដីដើម្បីឲ្យមកជួបជុំពិគ្រោះកិច្ចការណាមួយក្នុងទីណា, ទីនោះហៅថា "ទីប្រជុំ" ។ មួយទៀត ដំណើរត្រូវគ្នាដែលមិនមានការហៅរក ហើយស្រាប់តែជួបជុំគ្នាក្នុងទីណាមួយក៏ហៅថា "ទីប្រជុំ" បាន, ទោះបីទីប្រជុំជាផ្លូវការក្ដី មិនមែនជាផ្លូវការក្ដី ។ កិច្ចការណាមួយដោយផ្ទាល់ខ្លួន ឬកិច្ចការរបស់សមាគមឬក៏កិច្ចការរបស់រដ្ឋាភិបាល ។ កិច្ចការទាំងនេះសុទ្ធតែជាប់ទាក់ទង ដោយមនុស្សត្រូវហៅរកមនុស្សជាដំបូង គឺយកមនុស្សជាអ្នកបំពេញកិច្ចការ ។ កាលបើមនុស្សបានជួបជុំគ្នាបានប្រទះឃើញមុខគ្នា ក៏រមែងមានការបញ្ចាគ្នា, មានរឿងនិយាយប្រាស្រ័យរកគ្នា, សាកសួរគ្នាទៅវិញទៅមកពីនេះពីនោះ ឬសួរសំឡេងមាត់ពាក្យស្ដីផ្ទាល់ក្ដាយក៏មាន ប្រកែកឆ្លើយតគ្នាគោកកាកឡូឡាដោយឥតសណ្ដាប់ធ្នាប់ ក៏មាន ។ នេះជាធម្មតារបស់មនុស្សដែលមិនមានសីលធម៌សម្រាប់ទីប្រជុំ ។

ទីប្រជុំគ្រប់កន្លែងដែលមានប្រជាជនព្រមច្រើនឬ

តិចក៏ត្រូវមានច្បាប់ទម្លាប់ដូចយ៉ាងប្រកាសឬបទបញ្ញត្តិ សម្រាប់ទីប្រជុំ ដើម្បីឲ្យទីប្រជុំនិមួយ ៗ មានរបៀបសណ្ដាប់ធ្នាប់ល្អ ដូចបញ្ញត្តហាមប្រាមអំពីការទទួលទានស្លាបារី, អំពីការដណ្ដើមនិយាយច្រើននាក់មិនចេះស្ដាប់គ្នា, អំពីការនិយាយច្រើនតែម្នាក់ឯងមិនទុកឱកាសឲ្យគេនិយាយផង, អំពីពេលវេលាចូលចេញរបស់ទីប្រជុំដែលមានកំណត់ ដើម្បីឲ្យមានសីលធម៌រៀបរយសម្រាប់ទីប្រជុំឲ្យទីប្រជុំមានតម្លៃល្អតទៅ ។

ប្រជាជនដែលមានខ្លួនឬជាសមាជិកត្រូវ ចូលទៅកាន់ទីប្រជុំនីមួយ ៗ ត្រូវតែស្គាល់ឋានៈរបស់ខ្លួន, របស់អ្នកដទៃផង ទើបឈ្មោះថា អ្នកមានសីលធម៌ក្នុងទីប្រជុំ ។ វេលាដែលឈរឬអង្គុយក៏ត្រូវតែដឹងស្គាល់ទីកន្លែងដ៏សមគួរដល់ខ្លួនគ្រប់ ៗ គ្នា ពេលដែលត្រូវនិយាយក្ដី, នៅស្ងប់ស្ងៀមក្ដីក៏ត្រូវនិយាយឬត្រូវឈប់ឲ្យស្ងប់ស្ងៀម តាមច្បាប់បញ្ញត្តិរបស់ទីប្រជុំជាដរាប ។ ច្បាប់ព្រះពុទ្ធសាសនាសំដែងថា" អ្នកដែលមានសតិនឹងសម្បជញ្ញៈស្គាល់ហេតុផល, ស្គាល់កាលវេលា, ស្គាល់ចិត្តថ្លើម ចេះថ្លឹងអធ្យាស្រ័យរបស់បរិស័ទលោកហៅថា "មនុស្សសប្បុរស" គឺមនុស្សមានសីលធម៌ហ្នឹងឯង ។ ព្រោះហេតុនោះបានជារដ្ឋាភិបាលក្ដី, រដ្ឋសភាក្ដី, សាលាបង្រៀនក្ដី, ក្រសួងត្រសួងការណាមួយ មានការរបស់សមាគមជាដើម ដែលមានមនុស្សអ្នកធ្វើការប្រចាំទីកន្លែងនោះ ៗ ត្រូវតែមានច្បាប់ទាំងអស់ ដើម្បីឲ្យស្រួលដល់កិច្ចការគឺត្រូវតែមាននាយក មានប្រធាន, មានចាងហ្វាង, នាយត្រួតត្រា, នាយមន្ទីរ, នាយផ្នែក, នាយបញ្ជាការ, នាយបុគ្គលិក សម្រាប់មើលការ ពិនិត្យត្រួតត្រាគ្រប់ទីប្រជុំផ្លូវការទាំងអស់ ។ របៀបកិច្ចការដែលបង្កើតច្បាប់ឲ្យមាននាយក,មានប្រធានទាំងនោះមិនមែនដើម្បីប្រយោជន៍អ្វីទេ គឺប្រយោជន៍ចំពោះតែកិច្ចរៀបចំចាត់ការ ឲ្យមនុស្សអ្នកធ្វើការ មានសីលធម៌ គឺឲ្យមានរបៀបបែបបទទៀងបានត្រឹមត្រូវផង ឲ្យបានចំរើនដល់ការរបស់ប្រទេស ឬសាសនាផង ប៉ុណ្ណោះ ។

ទីប្រជុំចាត់ការទាំងអស់ដូចរៀបរាប់មកខាងលើនេះ, បើគ្មានមនុស្សអ្នកមានសីលធម៌, ទីប្រជុំនោះៗក៏មិនបានឈ្មោះថា ទីប្រជុំដែលល្អបានឡើយ ។ ធម្មតាទីប្រជុំដែលមានមនុស្សច្រើននាក់នោះ ជាការលំបាកបំផុត កម្រនឹងមានរបៀបរៀបរយគ្រប់យ៉ាង, បើប្រធានរបស់ទីប្រជុំនោះមានសមត្ថភាព ទើបទីប្រជុំមានរបៀបល្អផង, ចំរើនកិច្ចការផង ។ សមាជិកអ្នកចូលកាន់ទីប្រជុំកាលបើមានច្រើននាក់, មានៈសេចក្ដីយល់ក៏ច្រើនផ្លូវដែរ, លុះបានមកជួបជុំគ្នាត្រូវពិភាក្សាការណាមួយ ក៏រមែងយល់ខ្លួនប្រណាំងប្រជែងគ្នាខ្វះមិនខាន ជួនកាលផ្អែកតាមហេតុការណ៍ជាយុត្តិធម៌, ជួនកាលផ្អែកតាមសេចក្ដីប្រកាន់អស្មិមានះ កម្រនឹងស្របគ្នាបានឡើយ ។ ជួនកាលទាស់ទែងឈ្លោះគ្នាប្រទូស្តនឹងគ្នា ដោយមាត់ពាក្យក៏មានដោយកាយក៏មាន ។ ទីប្រជុំបែបនេះ ឈ្មោះថាទីប្រជុំខ្វះ

សីលធម៌ ។ ព្រោះហេតុនោះទីប្រជុំនីមួយៗ ត្រូវជ្រើសរើសបុគ្គលជាប្រធាន ឲ្យបានមនុស្សជាសប្បុរស គឺមនុស្សល្អដែលមានសីលធម៌ផង មានសមត្ថភាពគ្រប់គ្រាន់ផង ដើម្បីគ្រប់គ្រងមើលការឬរម្ងាប់នូវហេតុការគ្រក់ដែលកើតឡើងក្នុងទីប្រជុំ ។

មនុស្សសប្បុរសមិនមាននៅក្នុងពួកណា, ពួកនោះមិនឈ្មោះថាជាទីប្រជុំល្អបានឡើយ ។ ព្រោះទីប្រជុំនោះមិនប្រកបដោយលក្ខណៈ, មិនសម្រេចប្រយោជន៍ដល់ប្រទេសជាតិដោយល្អបានឡើយ ទីប្រជុំបែបនេះឈ្មោះថាមិនមានសីលធម៌ ។

ការប្រជុំរឿយៗនេះ ជាការប្រសើរបំផុត ដែលនាំឲ្យជាតិសាសនាបានចំរើនជាប្រាកដ ។ ក្នុងលិច្ឆវិអបរិហានិយធម៌ មានសេចក្ដីដំណាលថា "ពួកលិច្ឆវិជនក្នុងក្រុងវេសាលី ឧស្សាហ៍ប្រជុំគ្នាជានិច្ច ។ ការប្រជុំនោះក៏មានលក្ខណៈប្រកបដោយសីលធម៌ល្អណាស់, កាលដែលចូលកាន់ទីប្រជុំក៏មានសាមគ្គីធម៌ចូលជួបជុំត្រូវតាមកាលបរិច្ឆេទ ឥតរយីករយាក, លុះដល់ពេលក្រោកចេញពីទីប្រជុំ ក៏មានសាមគ្គីធម៌ឥតមានអ្នកណាមួយចេញរហេតរហូតដោយគ្មានធុរៈឡើយ, ពួកលិច្ឆវិស្លៀកពាក់ក៏ស្អាតល្អណាស់ដូចជាទេវតា ។ ការប្រជុំនេះជាករណីយកិច្ចមួយដែលអាចនាំមកនូវសេចក្ដីចំរើនដោយពិត ព្រោះជាហេតុឲ្យបានដឹង បានឮ បានឃើញសេចក្ដីជំនុំនោះជាមួយគ្នា, យល់ស្របជាមួយគ្នា ព្រមដោយសាមគ្គីធម៌ៗការប្រជុំរឿយៗដោយមានគ្នាច្រើនកុះករ សូម្បីទីប្រជុំយ៉ាងថោកទាបរបស់ពួកអ្នកលេងល្បែង ក្អាល់គឺរមែងសម្រេចប្រយោជន៍តាមថ្នាក់នៃទីប្រជុំរបស់គេជាប្រាកដៗ

ទីប្រជុំតូចក្ដី ធំក្ដី របស់ប្រជាជនដែលមានសណ្ដាប់ធ្នាប់ល្អ, មានរបៀបរៀបរយ ដោយការមិនមានមនុស្សអ្នកឈ្លោះទាស់ទែងគ្នាក្ដី មិនមានចោរលួចឆក់ដណ្ដើមក្ដី មិនមានមនុស្សនិយាយឡូឡាដែលនាំឲ្យរំខានដល់មនុស្សអ្នកសប្បុរសក្ដី ទីប្រជុំនេះឈ្មោះថាមានសីលធម៌ ។ ចប់ ។

ព្រះ។ បាលវង្ស សូរ-ហាយ

---

# ដំណើរ

សម្ដេចព្រះមហាសុមេធាធិបតី ជ.ណ.
ជោតញ្ញាណោ សង្ឃនាយក គណៈមហានិកាយ
និមន្តទៅកាន់ប្រទេសភូមា

ដោយមានសេចក្ដីនិមន្តអំពីព្រះតេជព្រះគុណ ញ៉ោងយ៉ានសាយ៉ាង ក្នុងនាមនៃភិក្ខុសង្ឃប្រទេសភូមា និងអំពីសភាសហភាពពុទ្ធសាសនាប្រទេសភូមា ដើម្បីសូមពាគ្រោះប្រឹក្សា រឿងប្រជុំឆដ្ឋសង្គាយនា (សង្គាយនា ទី ៦) ដែលនឹងចាប់ផ្ដើមធ្វើនៅថ្ងៃពេញបូណ៌មី វិសាខ ឆ្នាំមមី ឆស័ក តទៅនោះ, សម្ដេចព្រះមហាសុមេធាធិបតី ជ.ណ. ជោតញ្ញាណោ ដែលមានព្រះគ្រូសង្ឃសត្ថា ប.ស. ធម្មាភោមា និងគហបតីអ៊ឹង-គិមង៉នទៅតាមផង, បាននិមន្តចេញដំណើរដោយ



យន្តហោះពីរាជធានីភ្នំពេញ ទៅកាន់ក្រុងទេពមហានគរ (បាងកក) នៅថ្ងៃទី ១៧ មីនា ១៩៥៣ ឆ្ពោះទៅកាន់ប្រទេសភូមា ។

លោក អគ្គរាជទូត ប្រទេសខ្មែរ, លាវ, យួន និង មន្ត្រីអគ្គរាជការជាតិសៀមខ្លះព្រមទាំងព្រះសង្ឃនិងគ្រហស្ថ ជាតិខ្មែរនិងសៀមជាច្រើនរូប បានមករង់ចាំទទួលសម្ដេច នៅស្ថានីយអាកាសយាន "ដនមឿង" ក្រុងបាងកក ។

មុននឹងចេញដំណើរ ទៅក្រុង រង្គូន សម្ដេចត្រូវឈប់រង់នៅក្រុងបាងកកដរាបដល់ថ្ងៃព្រហស្បតិ៍ទី ១៩ មីនា ។ សម្ដេចសំណាក់នៅវត្តបញ្ចមបពិត្រ ដែលជាវត្តរបស់សម្ដេចព្រះវន្នរ័ត ប. កិត្តិសោភណោ សង្ឃនាយកប្រទេសសៀម ។ ក្នុងរយៈកាលនេះ សម្ដេចបាននិមន្តទៅជួបគាល់សម្ដេចព្រះមហាសង្ឃរាជ និងសម្ដេចសង្ឃនាយក, បាននិមន្តទៅ នមស្ការបូជនីយស្ថានសំខាន់ៗ មានព្រះពុទ្ធរូបព្រះជិនស្រីជាដើម ។ ក្រៅពីនេះសម្ដេចបានទទួលជួបនឹងពុទ្ធបរិស័ទទាំងព្រះសង្ឃទាំងគ្រហស្ថជាតិខ្មែរនិងជាតិសៀម ដែលមកសូមថ្វាយបង្គំគាល់គ្រប់ពេលស្ទើរឥតមានល្ហែ ។

ថ្ងៃទី ១៩ មីនា វេលាថ្ងៃត្រង់ សម្ដេចដោយមានពុទ្ធបរិស័ទអ្នកក្រុងបាងកកហែហមទៅផង បាននិមន្តទៅដល់ស្ថានីយអាកាសយាន "ដនមឿង" បន្តដំណើរ

រត្ថាះទៅក្រុងរ៉ង្គូន ដោយយន្តហោះសហភាពប្រទេសភូមា ៗ ម៉ោង ១៤ និង ៤៥ នាទី (ម៉ោងប្រទេសភូមា) យន្តហោះបានទៅដល់ស្ថានីយ "មង្គលដុន" ក្រុងរ៉ង្គូន ប្រទេសភូមា ៗ គួរឲ្យប្លែកចិត្តណាស់ យន្តហោះនោះតូចល្មមទេ ប៉ុន្តែមានកង្ហារបួន ពុំមានអ្នកដំណើរណាម្នាក់ទៅជាមួយសោះ មានតែគណៈប្រតិភូខ្មែរប៉-រូបដែលមានសម្តេចជាប្រធាននឹងកម្មការយន្តហោះប៉ុណ្ណោះឯង ហាក់ដូចជាយានពិសេស ៗ នាស្ថានីយ "មង្គលដុន", ព្រះភិក្ខុសង្ឃជាច្រើនរូបនឹងលោកប្រធានពុទ្ធិកសមាគមប្រទេសភូមា, លោកតំណាងនាយករដ្ឋមន្ត្រី, លោកប្រធានរដ្ឋសភា, លោកតំណាងក្រសួងធម្មការ ហើយនិងលោកតំណាងសមាគមខាងពុទ្ធសាសនាជាង ២០ សមាគមបានមកនៅរង់ចាំទទួល ៗ គ្រាន់តែសម្តេចនិមន្តចុះផុតពីជណ្តើរយន្តហោះ អ្នកខ្លះ



បើកឆ័ត្រប៉ាំងប្រគេនអ្នកខ្លះ លើកស្លួយទ្រួយដម្លូព្រិក្ស (ព្រិង) ជាមង្គលនិងទង់ ដើរហែហមអមសម្តេចនិមន្តទៅកាន់រថយន្តដ៏វិចិត្រ រៀបចំក្បួនហែចូលទៅកាន់ក្រុងតាមផ្លូវចម្ងាយ ១៨ គីឡូម៉ែត្រ ៗ ក្បួនហែនោះធំណាស់ មានភ្នាក់ងារព្រះនគរបាលជិះទោចក្រយានយន្តនាំមុខ, មានរថយន្តតូរ្យតន្ត្រី, រថយន្តដែលរចនាជាសំពៅ, ជារូបនាគ ៗ បន្ទាប់មកមានរថយន្តបាំងក្លស់មួយគូទើបបានដល់រថយន្តសម្តេច ដែលជារថបើកដំបូលរៀបជាបល្ល័ង្កប្រគេនសម្តេចគង់ មានឧបាសកពីរនាក់តែងខ្លួនជាព្រះឥន្ទព្រះព្រហ្ម បើកបាំងស្វេតច្ឆត្រមួយគូប្រគេនជាកិត្តិយសសម្រាប់ព្រះសង្ឃរាជ ៗ មានរថយន្តប្រហែល ៤០ បើកបរបន្តពីខាងក្រោយ ៗ ភ្នាក់ងារព្រះនគរបាលនិងឧបាសកឧបាសិកា នាំគ្នាឈរអមតាមចិញ្ចើមថ្នល់ ចាំសំពះផ្គងគារវការពចំពោះសម្តេច ៗ អស់រយៈពេលមួយម៉ោងនិង ៣០ នាទី ទើបក្បួនហែចូលដល់ក្រុង ទៅគោរពសក្ការចេតិយ ៗ នៅទីនោះ មានក្បួនចាំទទួលយ៉ាងឧឡារិក គឺមាន



(នៅមានត)

## សេចក្តីថ្លែងការណ៍នៃសមាគមមិត្តសាលាបាលី

កាលពីថ្ងៃទី ២៧ ខែ ធ្នូ ១៩៥៣ ពេលម៉ោង ៣ កន្លះរសៀល, សមាគមមិត្តសាលាបាលីបានធ្វើមហាសន្និបាតបោះឆ្នោត ជ្រើសរើសក្រុមអភិបាល

សម្រាប់ឆ្នាំ ១៩៥៤ នៅសាលាបាលីវត្តលង្កា ក្រោមអធិបតីភាពនៃលោកប្រធាន ក៉យ-ប៊ុក ។

ក្នុងឱកាសនោះ មានសមាជិកមកជួបជុំទាំងព្រះសង្ឃទាំងគ្រហស្ថចំនួន ១៥០ រូប ។ ចំណែកព្រះសង្ឃ មានសម្ដេចព្រះធម្មលិខិត• គួមប្រឹក្សាវត្តលង្កា, ព្រះពោធិវង្សចាន់ហ្វាន់សាលាបាលីជាន់ខ្ពស់, ព្រះញាណកោសល ញាណ-ឈឹន, ព្រះពុទ្ធវង្ស កៅ-ស៊ុម ជាដើម ព្រមទាំងព្រះថេរានុថេរៈ ឯទៀតជាច្រើនអង្គ ។ ខាងគ្រហស្ថ, គេបានឃើញឥស្សរជនទាំងឡាយមាន ឯ.ឧ. ក៉យ-លុត, ឯ.ឧ. អ៊ុក-ឆុប, ឯ.ឧ. ឡាំ-ឯម ជាដើម មួយអន្លើដោយក្រុមអភិបាលចាស់ទាំងអស់ ព្រមទាំងសិស្សចាស់និងមិត្តនៃសាលាបាលីឯទៀតៗ ជាច្រើនដែលយើងសូមអភ័យទោសដោយពុំបានកត់ឈ្មោះក្នុងទីនេះ ។

មុនដំបូង, លោកប្រធាន ក៉យ-ប៊ុក បានបើកឱកាសមហាសន្និបាត ដោយថ្លែងសុន្ទរកថាយ៉ាងក្បោះក្បាយដែលយើងនឹងចុះផ្សាយតទៅខាងមុខ, បន្ទាប់មក, ទើបលោកអគ្គហេរញ្ញិក អ៊ុច-រស់ បានចាត់ឲ្យលោកអនុហេរញ្ញិក មៅ-ម៉ី ថ្លែងការជំនួសអំពីមុខចំណូល-ចំណាយនៃសមាគមក្នុងឆ្នាំ ១៩៥៣ (សេចក្ដីថ្លែងការមុខចំណូល - ចំណាយនេះនឹងចុះផ្សាយតទៅខាងមុខដែរ) ។

បន្ទាប់មកទៀត, សមាជិកទាំងឡាយក៏បានរៀបចំការិយាល័យបោះឆ្នោត ដោយបានជ្រើសតាំងក្រុមអភិបាលបណ្ដោះអាសន្ន ៣ រូបគឺ ឯ. ឧ. ឡាំ-ឯម ប្រធាន, លោក ឌី-វ៉ង់ និងសៅ-វ៉ែន ជាលេខាធិការ ។ ក្នុងការបោះឆ្នោតនេះ, គេបានសរសេរនាម :

លោក ក៉យ-ប៊ុក, ម៉ម-វ៉ៃម, ផេង-ជ្រីវ, តែ-ផុន, អ៊ុច-រស់, មៅ-ម៉ី, មាស-ម៉ន, ចាប-ពិន, សាម-ឡាមុត, អ៊ូ-គង់, ឯ.ឧ. សម-ញាណ, លោកស្វាយ-ក៉, អ្នកស្រីយូ-អ៊ី, លោកថៃ-លី, អ៊ុក-ផង់, ប៉ក់-សាមេត, ញូង-សៀង, ក៉-ស៊ុយន, ឧបាសិកាពិន, លោក ហួត-ហៀម, ឌី-ផុន, សួរ-សារិន, សម-ថាំង, អ្នកស្រីគង់-ស, អ្នកស្រីក៉យ-ប៊ុក, អ្នកស្រីលេខា, ឯ.ឧ. ក៉យ-លុត, លោកកែប-អ៊ុល, ប៊ឹង-ហ៊ាត ។

ក្នុងចំនួនឈ្មោះទាំងអស់នេះ, គេបានសម្រេចបោះឆ្នោតសម្ងាត់ជ្រើសរើសយកតែ ១១ រូប ដើម្បីធ្វើជាក្រុមអភិបាល ។

ក្នុងទីបំផុត, គេបានឃើញនូវលទ្ធផលនៃការបោះឆ្នោតដូចតទៅនេះគឺ: លោកក៉យ-ប៊ុក អធិបតី, លោក សម-ថាំងនិងអ្នកស្រីគង់-ស អធិបតីរង, លោកផេង-ជ្រីវលេខាធិការ, លោកម៉ម-វ៉ៃមនិងលោកតែ-ផុន អនុលេខាធិការ, លោកអ៊ុច-រស់អគ្គហេរញ្ញិក, លោក មៅ-ម៉ី និងអ្នកស្រីលេខាអនុហេរញ្ញិក, លោកចាប-ពិន និង លោកមាស-ម៉ន បណ្ណារក្ស ។

ចំណែកអស់លោក-អ្នកឯទៀតដែលមិនបាន ជាប់ឆ្នោតជាក្រុមអភិបាលនោះ, សមាគមបានសុំយកធ្វើជាទីប្រឹក្សា ទាំងអស់គ្នាទៅ ។

---

សុន្ទរកថានៃលោកអធិបតី

. . . . . . . . . . . . . . . . . . . . .

. . . . . . . . . . . . . . . . . . . . .

សេចក្ដីថ្លែងអំពីមុខចំណូល - ចំណាយ

. . . . . . . . . . . . . . . . . . . . .

. . . . . . . . . . . . . . . . . . . . .

## សេចក្ដីថ្លែងអំពីមុខចំណូលចំណាយ

ប្រាក់ចំណូលក្នុងឆ្នាំ១៩៥៣- ១៣២.៧៣៧រ,៩០

ប្រាក់ចំណាយ –„– - ៨២.៥៨៣រ,៤៧

### រាយមុខចំណូល

| | |
|---|---|
| ១-ចំណូលពីសមាជិកក្នុងក្រុង | ១២.៤៦៧រ,០០ |
| ២-ចំណូលពីសាខាសមាគម | ៤.៣៩១រ,០០ |
| ៣-អំពីលក់បណ្ណសមាជិក | ៤.៤៤០រ,០០ |
| ៤-អំពីលក់សៀវភៅបញ្ហាសាមគ្គី | ៤.០៤០រ,០០ |
| ៥- សំណងពីទស្សនាវដ្ដី ឆ្នាំ ១៩៥១ -៥២ | ១៦.១៧០រ,០០ |
| ៦-អំណោយព្រះសារីរិកធាតុ | ៦២.០០០រ,០០ |
| ៧-សំណល់អំពីការធ្វើទីសំណាក់ការ | ១.៩៩៩រ,០០ |
| ៨-ប្រាក់សល់ពីឆ្នាំចាស់ | ២៩.២៣០រ.៩០ |
| បូករួម ... | ១៣២.៧៣៧រ.៩០ |

### រាយមុខចំណាយ

| | |
|---|---|
| ១- សម្រាប់បៀវត្សបុគ្គលិក២រូប | ១៤.៤០០រ,០០ |
| ២- ទិញតុ ទូទីងសម្ភារប្រើប្រាស់ប៊ុយរ៉ូ | ៦១១៧រ,៥០ |
| ៣- ផ្ញើទស្សនាវដ្ដីបញ្ហាសាមគ្គីទីង លំវិតផ្សេង ៗ | ១.១០៤រ,៥០ |
| ៤- បោះបណ្ណសមាជិក | ១៤០០រ,០០ |
| ៥- ចំណាយធ្វើបុណ្យព្រហ្មទានទីង ចែករង្វាន់សាលាបាលីរងខេត្តក្រៅ | ៤៩៧១រ,៥០ |
| ៦-ប្រគេនសម្ដេចទិមន្ដទៅប្រទេសភូមា | ២០០០រ,០០ |
| ៧-ប្រគេនលោកពីរអង្គទៅសិក្សា នៅប្រទេស នេប៉ាល | ២០០០រ,០០ |
| ៨- ប្រគេនព្រះពោធិវង្សបំពេញបេសកកម្ម ផ្នែកខាងសាសនានៅប្រទេសថៃ | ១០០០រ,០០ |
| ៩- ព្យាបាលពេតសម្ដេចវត្តលង្កា | ១០០០រ,០០ |
| ១០- ចំណាយបង្គ្រប់លើទស្សនាវដ្ដី ឆ្នាំ ១៩៥២ | ១៩០០០រ, |
| ១១- ចំណាយបោះពុម្ពសៀវភៅ បញ្ហាសាមគ្គី | ១៧៥៥០រ,០០ |
| ១២- បោះលិខិតអញ្ជើញគៀវធ្វើ មហាសន្និបាត | ១៧០រ,០០ |
| ១៣- ធ្វើសន្និសិទ្ធ៣លើក | ៣៨៥រ,០០ |
| ១៤- ចាយខ្សែល្លួសថ្វាយពរព្រះករុណា នៅប្រទេស អាមេរិក | ២៧១រ.៩៧ |
| ១៥- រៀបលៀងភោជនាហារគណៈប្រតិភូ | |

ពុទ្ធសមាគមថៃ ១៩៨៦៛.០០

១៦- ជួសជុលហោត្រៃដែលសម្តេចប្រទាន

ជាមន្ទីរស្នាក់ការសមាគមសព្វថ្ងៃនេះ ៧២២៧៛.០០

១៧- ចូលបុណ្យសាងព្រះវិហារនៅ

លុម្ពិនី(នេប៉ាល់) ១·០០០៛០០

បូក... ៨២·៥៨៣៛៤៧

បានឃើញអធិបតី អគ្គហេរញ្ញិក

ក៉យ-ប៊ុក អ៊ុច-សំ

## សុន្ទរកថា

### នៃលោកអធិបតី

សូមពិតពុទ្ធដីកា ព្រះថេរានុត្ថេរៈទាំងឡាយ' និងសូមជំរាបអស់លោក-អ្នកទាំងឡាយ

សូមតានស្រាប សូមស្រាប ៗ

ខ្ញុំព្រះករុណា ខ្ញុំបាទសូមថ្លែងនូវសេចក្ដីអំណរយ៉ាងក្រៃលែង, ដែលបានមកជួបជុំចំពោះព្រះតេជៈគុណ និងលោក-អ្នកដែលបាននិមន្តនិងអញ្ជើញមក ក្នុងមហាសន្និបាតនេះទុកជាកិត្តិយសយ៉ាងប្រពៃនៃសមាគមនេះ, ព្រោះថាសមាគមនេះដែលនឹងបានចំរើនដុះដាលមានវឌ្ឍនភាពវែងឆ្ងាយ តាំងពីដើមរៀងរបមកក៏អាស្រ័យមកអំពីព្រះសង្ឃ និងគ្រហស្ថទាំងអស់ជាអ្នកជួយឧបត្ថម្ភ គាំទ្រឲ្យសមាគមមានសភាពផ្សាយទូទៅ ក្នុងខេត្ត-ស្រុក-ឃុំផ្សេង ៗ ក្នុងព្រះរាជាណាចក្រទាំងមូល,

សកម្មភាពទាំងនេះ គឺមកអំពីព្រះតេជ-គុណនិងលោក-អ្នកជួយជាកំឡាំងធនធាន១ៈ ជួយផ្សាយដោយកំឡាំងកាយកាយ១ៈ ជាហេតុនាំឲ្យសមាគមនេះ បណ្ដុះធម៌សាមគ្គី គឺការចងបាច់រវាងគ្នានិងគ្នា ឲ្យរឹងប៉ឹងឡើងជាទុក្ខមគតិដ៏ថ្លៃថ្លា ចំពោះជាតិសាសនា ព្រះមហាក្សត្រិយ៍ ក្នុងកម្ពុជរដ្ឋទាំងមូល ឲ្យបានស្ថិតស្ថេរបវរកាលតទៅក្នុងអនាគត ។

កិច្ចការដែលយើងចងបាច់គ្នានេះ មានអានុភាពខ្លាំងខ្លួនជាអស្ចារ្យទូទៅគ្រប់ទិសានុទិស បើមានពួកក្រុមណាអាចបង្កើតមានឡើងបាន ពួកក្រុមនោះ រមែងបានប្រកបដោយសេចក្ដីចំរើនរួសរាន់ទាន់ពេលវេលាដែលត្រូវការ ។

វគ្គបំណង ដែលសមាគមចាត់ការរួបរួមសិស្សានុសិស្សទាំងព្រះសង្ឃ ទាំងគ្រហស្ថ ក្នុងព្រះរាជាណាចក្រទាំងមូលមាន ១៦ សាខា គឺៈ

១- សាខា សមាគមមិត្តសាលាបាលី ខេត្តកំពត

២- –„– „ តាកែវ

៣- –„– „ ព្រៃវែង

៤- –„– „ កំពង់ធំ

៥- –„– ទឹកថោ-បាត់ដំបង

៦- –„– សិរីសោភ័ណ –„–

៧- –„– មោងឬស្សី (បាត់ដំបង)

៨- –„– ខេត្តពោធិសាត់

៩- –„– ស្រុកបាកាន

១០- –„– „ ក្រគរ

១១- សាខាសមាគមមិត្តសាលាបាលី ឃុំផ្ទះរង

១២- –„– ឃុំតាលោ

១៣- –„– ស្រុកដីក្រែង

១៤- –„– ស្រុកមេមត់

១៥- –„– ស្រុកកៀនស្វាយ

១៦- –„– ខេត្តកំពង់ធំ

បណ្តាសាខាសមាគមទាំងនេះ សាខាខ្លះបានចម្រើន, ខ្លះនៅមិនទាន់ចំរើនលូតលាស់នៅឡើយ, ព្រោះខ្វះការជួយឧបត្ថម្ភ និងការផ្សាយឃោសនាដោយមុតមាំ ព្រមទាំងខ្វះធនធានមិនគ្រប់គ្រាន់ល្មមឲ្យអ្នកចាត់ការពន្យល់ឲ្យសព្វគ្រប់ទៅបាន ។

កិច្ចការពន្យល់ឲ្យភិក្ខុសង្ឃនិងគ្រហស្ថជ្រួតជ្រាបនូវកិច្ចការសមាគមនិមួយ ៗ មិនមែនជាកិច្ចងាយទេ, ព្រោះអ្នកខ្លះមិនយល់នូវឧត្តមប្រយោជន៍ ក្នុងព្រះពុទ្ធ-សាសនា ដោយជាក់លាក់ ព្រមទាំងមានចិត្តប្រកបដោយមច្ឆរិយៈ ស្អិតស្អាញផង ក៏ក្លាយទៅជាស្តាប់មិនឮផងក៏សឹងមាន ។

តែតទៅអនាគតនេះ យើងមានសេចក្តីសង្ឃឹមយ៉ាងមាំថា ក្រុមអភិបាលថ្មីនិងចាត់ដំណើរការទៅតាមថ្នាក់តាមជាន់ ឲ្យបានសាខានេះបានរីកធំទូលាយតទៅមុខទៀត ព្រោះបានទទួលសេចក្តីអនុគ្រោះពីសម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ ទ្រង់ជួយម៉ាស៊ីន រូណេអូ ល្មមបោះពុម្ពផ្សាយទិនបណ្ណ ឬ លិខិតណាមួយ ដែលសម្រាប់ផ្សាយពន្យល់បំភ្លឺបព្វជិតនិងគ្រហស្ថ ឲ្យបានយល់ឆាប់ទាន់ពេលវេលា ដែលសមាគមបានគ្រោងទុកសមតាមបំណងជាមិនខាន ។

សូមព្រះតេជ-គុណ-លោកអ្នកជាសិស្សានុសិស្សជាមិត្តសាលាបាលីទាំងឡាយ គួរជ្រាបថា ប្រទេសនានាដែលគេមានសមាគម និងសាខាគេច្រើន ៗ ដូចជាប្រទេស ជប៉ុន-សៀម-ភូមា ជាដើម មានគេជួយឧបត្ថម្ភព្រះពុទ្ធសាសនា ឲ្យបានស្ថិតថេរចិរកាល, ព្រោះគេបានយល់ច្បាស់នូវឧត្តមប្រយោជន៍ក្នុង ការចងបាច់គ្នាជាពួកក្រុមសមាគម, មិនចំពោះតែត្រឹមពុទ្ធិកសមាគមពិភពលោកទេ មានច្រើនថ្នាក់ច្រើនជាន់ រហូតដល់ឧបាសិកា ក៏មានសមាគមផងដែរ ព្រោះហេតុនេះ ការរួបរួមសិស្សានុសិស្សមិត្តសាលាបាលីនេះ ជាកំឡាំងមួយយ៉ាងមាំមួន សម្រាប់ផ្តល់ប្រយោជន៍ឲ្យដល់សិក្ខាកាមកុលបុត្រ ដែលត្រូវការសិក្សាព្រះពុទ្ធសាសនា ក្នុងព្រះរាជអាណាចក្រ ឲ្យប្រកបដោយវឌ្ឍនភាព ជាគិយេក្កភាពតទៅ គឺ:

១- ជួយគ្នាតាមកំឡាំងកាយ-វាចា-ចិត្ត, គឺជួយជ្រោមជ្រែងដោយកំឡាំងធនធានខ្លះ ជួយផ្សាយទូទៅខ្លះ ឲ្យបានចំរើនតទៅ,

២- ជួយឧបត្ថម្ភអ្នកសិក្សាភាសាបាលីនិងភាសាជាតិ ដោយចែករង្វាន់ជាគ្រឿងលើកទឹកចិត្ត ឲ្យនឹងធឹងរឹតតែមានសទ្ធាដុះដាលឡើងដល់បច្ឆាជន-ភាជន តទៅអនាគត ។

ក្នុងពេលដែលកន្លងទៅហើយមុនៗ នេះសមាគមបានធ្វើបុណ្យព្រហ្មទានចំពោះ សិស្សដែលប្រឡងជាប់វិញ្ញាបនបត្រ សាលាបាលីជាន់ខ្ពស់កាល គ.ស. ១៩៥០-៥១-៥២, ព្រមទាំងចែកដល់សិស្សដែលប្រឡងឡើងថ្នាក់ជាប់លេខខ្ពស់ជាងគេ ក្នុងឆ្នាំ ១៩៥៣នេះផង,

ក្រៅពីនេះ សមាគមបានចែកសម្ភារៈចំពោះសាលាបាលីរងក្នុងព្រះរាជអាណាចក្រទាំងមូលគឺ

កាលពីឆ្នាំ ១៩៥២ បានចែកចំពោះសាលាបាលីរង ទាំង ១៤ វត្តក្នុងព្រះរាជធានី (ភ្នំពេញ)"

ឆ្នាំ ១៩៥២ បានចែកចំពោះសាលាបាលីរងខេត្តកណ្ដាល ចំនួន ៦៣ វត្តនិងសាលាធម្មវិន័យវត្តឧណ្ណាលោម ១ ជា៦៤ ។

ឆ្នាំ ១៩៥៣ សមាគមបានរៀបចំចែកបន្តពីឆ្នាំមុនបានចំនួន៥៧ វត្ត ដែលមានឈ្មោះអស់លោក-អ្នកចូលបានចំនួន ៣៣ វត្តផង ។ ហើយសមាគមរៀបចំចែកចំពោះវត្តក្នុងខេត្ត ឬ ស្រុកដែលមានសាខាសមាគមជាប្រមុខគឺ :

| | | | |
|---|---|---|---|
| ខេត្ត | កំពង់ធំ | ៧ | វត្ត |
| " | តាកែវ | ១៩ | " |
| " | ពោធិសាត់ | ១២ | " |
| " | កំពង់ឆ្នាំង | ៥ | " |
| " | ព្រៃវែង | ៣ | " |
| " | កំពង់ចាម | ៤ | " |
| ខេត្ត | សៀមរាប | ៣ | វត្ត |
| " | បាត់ដំបង | ៤ | " |

ការចែកសម្ភារៈ ដូចបានរៀបរាប់មកនេះចំពោះវត្តក្នុងខេត្តមានតែខេត្តពោធិសាត់មួយទេ ដែលចែកអស់ ក្រៅពីនោះនៅសល់វត្តច្រើនតទៅទៀត

– សមាគមមិត្តសាលាបាលី បានផ្ដើមបោះពុម្ពទស្សនាវដ្ដី "មិត្តសាលាបាលី" តាំងពីឆ្នាំ ១៩៥០ មកទល់នឹងឆ្នាំ ១៩៥២ តែពុំសូវមានអ្នកជាវ - ហើយសមាគម ក៏ខាតខុន, បោះពុម្ពតទៅទៀតមិនបាន, ទើបដល់មកឆ្នាំ ១៩៥៣ នេះបានផ្ដើមបោះពុម្ពសៀវភៅបញ្ហា សាមគ្គី" ចំនួន ៣០០០ ក្បាល ។

– ក្នុងឆ្នាំ ១៩៥៤ សមាគមនឹងប្រុងបោះពុម្ពទស្សនាវដ្ដី "មិត្តសាលាបាលី" តទៅទៀត, តែស្រេចនឹងក្រុមអភិបាលថ្មី ព្រមទាំងប្រុងនឹងបង្កើតឲ្យមានបណ្ណាល័យសម្រាប់សមាគមផង ។

សូមលោកអ្នកជួយឧបត្ថម្ភ ដោយធ្វើអំណោយចំពោះសមាគមនូវសៀវភៅផ្សេងៗ ជាភាសាបរទេស,

– សង្គ្រោះដល់សិស្សានុសិស្សដែលមានប្រាជ្ញាវាងវៃដែលចេញទៅរៀននៅប្រទេសក្រៅ :

សមាគមមិត្តសាលាបាលីបានរួបរួមជាមួយពុទ្ធិកសមាគមពិភពលោកមជ្ឈមណ្ឌលភូមិភាគកម្ពុជរដ្ឋ ធ្វើបុណ្យផ្កាបញ្ចូនបច្ច័យ ទៅជួយសាងព្រះវិហារនៅលុម្ពិនី (ប្រទេសនេប៉ាល់) ព្រមទាំងបញ្ជូនភិក្ខុពីររូបទៅរៀន ក្នុងប្រទេសនេះគឺ ៖

១-ព្រះត្រៃវិមលបញ្ញា បិយសីលោ-គង់-គូ នៅវត្តទណ្ណាលោម,

២-ព្រះមហាមុនីជោតោ អៀង-មាន នៅវត្តកោះ

ព្រះភិក្ខុទាំងពីររូបនេះ បានចេញដំណើរ ដោយអាកាសយាន (អែរវៃថ) ពីភ្នំពេញទៅ នៅថ្ងៃទី ៦ វិច្ឆិកា ១៩៥៣ នេះ ពេលម៉ោង ១៥ ។

ក្រៅពីនេះសមាគមបានរួបរួមជាមួយពុទ្ធិកសមាគមពិភពលោកមជ្ឈមណ្ឌលកម្ពុជរដ្ឋ ចាត់ទទួលព្រះសង្ឃភូមាមួយអង្គនិងឧបាសកមួយនាក់ ដែលនិមន្តនិងអញ្ជើញមកកាន់ព្រះរាជធានីក្រុងភ្នំពេញ ពីថ្ងៃទី៧មីនា, ១៩៥៣

ជូនដំណើរជាកិត្តិយស ចំពោះសម្ដេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ ដែលនិមន្តវិលត្រឡប់ពីប្រទេសភូមាវិញ ។

សមាគមបានធ្វើសន្និសីទ លើកទី ១ សម្ដេចព្រះមហាសុមេធាធិបតីសង្ឃនាយក,អំពីដំណើរនិមន្តទៅប្រទេសភូមាពីថ្ងៃទី ១៨ មេសា ១៩៥៣ នេះ ។

លើកទី ២ ឯ.ឧ-ង៉ិន-ទិប្ប រដ្ឋលេខាធិការនៃក្រសួងឃោសនាការ បានថ្លែងពី ទេសចរខ្មែរម្នាក់ធ្វើដំណើរទៅកាន់ប្រទេសឥណ្ឌៀសម័យបច្ចុប្បន្ន ពីថ្ងៃទី ២៨ មីនា ១៩៥៣ ។

លើកទី ៣ ឯ.ឧ.ង៉ិន-ទិប្ប អតីតរដ្ឋលេខាធិការនៃក្រសួងឃោសនាការ, បានថ្លែងអំពីការប្រជុំលើកទីពីរនៃគណៈកម្មការទេសចរណ៍ នៅក្រុងតូក្យូ កាលពីថ្ងៃទី ៣១ ឧសភា ១៩៥៣ ។

ចំណែកសមាជិកមាន:

| | |
|---|---|
| ជនកសមាជិក | ៣ នាក់ |
| ឧបការី „ | ៦ នាក់ |
| ទាយកសមាជិក | ៣២ នាក់ |
| កម្មិកសមាជិក | ៤៨២ នាក់ |
| ឧបាសកសមាជិក | ៣៦២ នាក់ |
| បូករួម | ៨៨៥ នាក់ |

ក្នុងអវសានកថានេះ ខ្ញុំព្រះករុណា, ខ្ញុំបាទក្នុងភាវៈជាអធិបតីនៃសមាគមមិត្តសាលាបាលី សូមអំពាវនាវដល់សិស្សានុសិស្សនៃមិត្តសាលា បាលីនេះឲ្យខំពួតដៃគ្នាក្នុងសាមគ្គីធម៌ដ៏ខ្ពង់ខ្ពស់ ដែលមានវត្ថុនិងសមានត្តតាធម៌ ជាស្នូលមាំទាំឲ្យសមាគមនេះឲ្យមានវិវត្តន៍ដ៏ធំទូលាយ សមរម្យជាសមាគមនៃពួកអ្នកចេះដឹងក្នុងកម្ពុជរដ្ឋទាំងមូល ។

សូមបួងសួង នូវប្រសិទ្ធិពរទាំង ៤ ប្រការ គឺ អាយុ-វណ្ណៈ-សុខ.ពលៈ គ្រប់ៗគ្នាកុំបីអាក់ខានឡើយ ។

## អក្សរសាស្ត្រខ្មែរ

ដកពីទស្សនាវដ្ដី កោទ • មក

លើផែនសិលានៅនាប្រាសាទបុរាណផ្សេងៗ ដែលមាននៅពាសពេញភូមិភាគ និគមជនបទនៃកម្ពុជរដ្ឋ, អក្សរសាស្ត្រនេះ មានតែងរឿងរ៉ាវតាមរបៀបវប្ប-

ធម៌ឥណ្ឌៀ មានព្រហ្មញ្ញសាសនាជាដើម ដោយកាលដំបូងព្រះបាទកៅណ្ឌិញ្ញៈ ជាក្សត្រសម័យនគរភ្នំ (Founan) ជាជាតិឥណ្ឌៀ បាននាំអក្សរនិងភាសាប្រទេសឥណ្ឌៀ ចូលមកកាន់ប្រទេសកម្ពុជាក្នុងរវាងចុងសតវត្សទី ២ ។ តាំងពីនោះមក ទើបមានសៀវភៅក្បួនខ្នាតខាងសាសនាព្រហ្មញ្ញ មានគម្ពីរត្រៃវេទ, ហរិវង្ស, បុរាណៈ, រាមកេរ្តិ៍, មហាភារតៈជា-ដើម ព្រមទាំងកាព្យឃ្លោងខាងសំស្ក្រឹតជាច្រើន ។

តែក្នុងគ្រានោះ, នគរភ្នំត្រូវពួកខាងចិនឡាវាយដណ្ដើមយកទៅបាន (គ.ស.៥៤០) ហើយតាំងរដ្ឋទាំងពីរប្រមូលរួមមកនៅក្នុងអាណាចក្រតែមួយ គឺប្រទេសកម្ពុជា អតីតសម័យអង្គរក្នុងសតវត្សទី ៦-៧។ ប្រទេសកម្ពុជាក្នុងសម័យនោះ បែរទៅជាមិនសូវសម្បូរក្បួនខ្នាតច្រើនវិញទេ, តាមផ្លូវនិងព្រៃ ក៏មិនសូវមានសិលាចារឹកដែរ ដោយប្រហែលជាអក្សរដែលសរសេរលើស្បែកសត្វជាដើម នោះពុកផុយរលួយ ឬបាត់បង់អស់ទៅ ។

យុគៈទី ២— តាំងពីសតវត្សទី ៧ មកដល់សតវត្សទី ១៤ សម័យនោះ អក្សរដែលចារឹកនៅផែនសិលានិង សសរថ្ម មានពីរបែប មួយបែបជាភាសាសំស្ក្រឹតដែលច្រើនតែងជាកវីនិពន្ធ, មួយបែបទៀតជាភាសាខ្មែរបុរាណជាអក្សរខមមូលដែលច្រើន ជាពាក្យរាយ ៗ លោក ស៊ក-សឺដែស អតីតចាងហ្វាងសាលាបារាំងសែសនៅចុងបូព៌ាប្រទេស បានយកសិ-លាចារឹកនោះមកពិនិត្យអក្សរ ហើយបកប្រែចេញជាសេចក្ដី ដោយបានប្រមូលរឿងរ៉ាវទាំងប៉ុន្មានមកបង្គ្រង ជាប្រវត្តិសាស្ត្រខ្មែរ ទុកជាគោលឲ្យឃើញថាពីសម័យនោះមក មានបុព្វហេតុនៃអក្សរសាស្ត្រខ្មែរវិវត្តន៍នៃអក្សរសាស្ត្រខ្មែរ, របាក្សត្រ, ប្រវត្តិការណ៍នៃសិលាចារឹក, ប្រាសាទផ្សេងៗ, ទំនៀមទំលាប់ខ្មែរ, សង្គម, សេដ្ឋកិច្ច, សាសនា, ក្រុមបណ្ឌិត្យ ។ល។ អក្សរសាស្ត្រខ្មែរ ក្នុងជំនាន់នោះបានបង្ហាញឲ្យយើងស្គាល់ប្រទេសកម្ពុជាថា មានគោលសំខាន់ ៣ យ៉ាងគឺប្រវត្តិសាស្ត្រ, សាសនា, កវីនិពន្ធជាភាសាសំស្ក្រឹត ។

តាំងពីសតវត្សទី ៨ មក, រដ្ឋចិនឡា បានបែងចែកជា ២ ភូមិភាគគឺ ចិនឡាគោក នៅខាង-ជើង, ចិនឡាទឹក នៅខាងក្រោម ។

ក្នុងសតវត្សទី ៩, ព្រះមហាក្សត្រជ័យវរ្ម័នទី២ ដែលជាបមនៃសន្តតិវង្សអង្គរ នឹងមហាក្សត្រឯ-ទៀត ៗ មកបានស្អាងប្រាសាទបុរាណជាច្រើនកន្លែងនិងបានស្អាងព្រះរាជធានីផ្សេងៗគឺៈ ហរិហរាលយបុរៈនៅខាងទិសក្លៀសាន សៀមរាបដែលសព្វថ្ងៃហៅថាស្រុករលួសយសោធរបុរៈ ដែលព្រះបាទយសោវរ្ម័នទី ១ បានស្អាង មានប្រាសាទបាខែងនៅកណ្ដាលក្រុង អង្គរធំដែលព្រះបាទជ័យវរ្ម័នទី ៧ បានស្អាងមានប្រាសាទបាយ័ន ឋិតនៅជាមជ្ឈដ្ឋាននៃក្រុង ។

តាំងពីសតវត្សទី ១២ តមក, មានសិលាចារឹក

ជាច្រើននៅប្រាសាទបុរាណទាំងឡាយគឺ អង្គរវត្ត, បាយ័ន, បន្ទាយក្តី, តាព្រហ្ម, ព្រះខ័ន; អង្គរវត្តទុកជាបូជនីយដ្ឋាន សម្រាប់តំកល់ព្រះធាតុនៃព្រះបាទសុរិយវរ្ម័នទី ២ ។ ចំណែកខាងព្រះបាទជ័យវរ្ម័នទី ៧ ទ្រង់បានសាងប្រាសាទជាច្រើន ហើយទ្រង់មានតេជានុភាពយ៉ាងអស្ចារ្យ បានកំចាត់ចាមឲ្យចេញផុតពីព្រះរាជអាណាចក្ររបស់ព្រះអង្គក្នុង គ.ស. ១១៧៧ ព្រះអង្គបានសាងមន្ទីរពេទ្យបាលរោគ ១០២ កន្លែងនិងសាលាសំណាក់នៅតាមផ្លូវថ្នល់ជាច្រើន ។ ក្នុងសម័យនោះមានបណ្ឌិតតែង "អំពីសព្វប្រណិធាននៃមន្ត្រីព្រះមហារាជសុរិយវរ្ម័នទី ១សតវត្សទី ១១" និងកម្ពុវិធីនៃមន្ទីរពេទ្យរបស់ព្រះបាទជ័យវរ្ម័នទី៧សឹងមាននៅក្នុងសិលាចារឹកសាយ-ហ្វុង ។ល។

យុគៈទី៣.– ពីសតវត្សទី១៤ (គ.ស. ១៥៩៣ រជ្ជកាលព្រះបាទជ័យជេដ្ឋាទី ១. សៀមវាយបន្ទាយលង្វែកយកបាន) ដរាបមកដល់សតវត្សទី ១៩ គឺ គ.ស. ១៨៦៣ – ក្នុងគ្រានេះហៅថាកលយុគគឺយុគខ្មៅ ព្រោះប្រទេសកម្ពុជាក្នុងសម័យនោះ កើតចលាចលវល់តែនឹងសៀម ហើយនឹងយួនវាយដណ្តើមយកទឹកដីនាំបង្កបង្កើតអសន្តិសុខពាសពេញទាំងប្រទេស អក្សរសាស្ត្រក្នុងពេលនោះចុះអាប់អោនជាខ្លាំងដោយប្រជាជនរវល់តែនឹងធ្វើចម្បាំងហើយនឹងរត់គួន, មានចួនកាលសៀមចាប់នាំយកទៅជាឈ្លើយខ្លះផង ។

យុគៈទី៤.— ពីសតវត្សទី ១៩ – យុគៈនេះចែកជា ២សម័យគឺ ១- សម័យទំនើប គិតក្នុងសតវត្សទី ១៩-២០ ដែលព្រះបាទសម្តេចព្រះអង្គដួងគ្រងរាជសម្បត្តិ (គ.ស. ១៨១៤ មកទល់នឹង ១៨៨៤) គឺឆ្នាំដែលប្រទេសកម្ពុជា បានចុះអនុសញ្ញាជាមួយនឹងប្រទេសបារាំង; ២- សម័យបច្ចុប្បន្ន គិតពីសតវត្សទី-២០ – ២១ (ពីគ.ស. ១៨៨៤) ។



ជាតិមានអ្វីជាកំឡាំង

សម័យនេះជាឱកាស ឬកាលៈទេសៈគួរទំនងដែលប្រទេសកម្ពុជាយើង ឈ្មៀងមើលដល់ជីវភាពរបស់ប្រជារាស្ត្រក្នុងព្រះរាជអាណាចក្រ ដែលចាត់ជាការចាំបាច់មួយបែប សម្រាប់ជំនួយកំឡាំងជាតិឲ្យរឹងប៉ឹងឡើង ៗ របស់សំខាន់ដែលសម្រាប់ធ្វើជាតិឲ្យបាន

វិនប៊ុននោះគឺអ៊ីៗ - គឺជនដែលសម្រាប់បន្តពូជពង្សទៅអនាគតមិនឲ្យលត់រលាយបាត់ បានដល់អនុជនគឺក្មេងៗ ការចិញ្ចឹមក្មេងឲ្យត្រូវតាមរបៀបច្បាប់អនាម័យ អាចធ្វើក្មេងនោះឲ្យមានរាងកាយធាត់ធំទឹងរឹងប៉ឹងល្អ ព្រមទាំងអាចបំបាត់ចោលស្រឡះនូវការយល់ខុស ឬវង្វេងគំនិតផ្សេងៗ ដែលជាប់តំណតាំងពីអតីតកាលមក ព្រោះប្រទេសតែងត្រូវការមនុស្សដែលគ្រប់គ្រាន់ដោយសមត្ថភាព គួរទឹងទាត់ថាជាពលរដ្ឋល្អ មានសីលធម៌និងអារ្យធម៌ប្រចាំជាប់ក្នុងដួងចិត្ត, បើមនុស្សបែបនេះចំរើនបានប៉ុណ្ណា វឌ្ឍនភាពរបស់ប្រទេសក៏នឹងមានប៉ុណ្ណោះដែរ ។

តាមសភាវៈការរស់នៅរបស់ប្រជាករក្នុងប្រទេសនីមួយៗ មិនថាប្រទេសធំឬតូចទេ អ្នកមានឋានៈស្ដុកស្ដម្ភតែងតែមានចំនួនតិចជាងអ្នកក្រីក្រជាដរាប គឺថាជនក្រីក្រមានទូទៅគ្រប់តំបន់ទាំងអស់ ។

ឯជនក្រីក្រទាំងនោះក៏តែងមាន គ្រួសារដូចជនមានសម្បត្តិដែរ ចំណែកទារកដែលចាប់កំណើតក្នុងគ្រួសារអ្នកក្រលំបាក តែងមានអាការៈប្លែកគ្នា ត្រង់ជីវភាពនិងការឧបត្ថម្ភមិនដិតដល់ ដូចជាទារកដែលកើតក្នុងត្រកូលស្ដុកស្ដម្ភនោះទេ, អស់លោកដែលនៅក្នុងព្រះរាជធានីក៏គង់បានប្រទះសភាពក្មេង ដែលមានសំលៀកបំពាក់ដាច់ដាចរយីករយាក ត្រាច់នៅក្បែរចិញ្ចើមថ្នល់ មានកាន់ចំពាមកៅស៊ូដើរបាញ់បក្សីផ្សេងៗដែលនៅលើរុក្ខជាតិ មានចាបស្រុក, ចៀបក្របាស ។ល។ ខ្លះជាអ្នកសូមត្រាច់ដើរតាមភោជនាគារដ្ឋានផ្សេងៗ ដោយមានអម្បែងកាន់នៅដៃ ខ្លះធ្វើជាកម្មករសែងលីនៅកំពង់ចំណតនាវាឬ ទីចំណតរថយន្តជាដើម ត្រូវបានរង្គាន់យ៉ាងស្អួចស្អើងមិនទាំងគ្រប់គ្រាន់តម្លៃអាហារក្នុងមួយថ្ងៃផង ជួនកាលក៏បានគ្រប់គ្រាន់ចំពោះខ្លួន តែបែកគ្រួសារផងមិនបាន ជួនកាលឃើញដើររើសអាហារសំណល់ក្នុងទីខ្លះយកទៅបំអែតផ្ទៃមួយពេលៗ ជនទាំងនេះស្ទើរតែរកសុខភាពប្រចាំខ្លួនពុំបានឡើយ គួរឲ្យកើតសំវេគចិត្តយ៉ាងក្រៃលែង ។

ពេលអាស្រ័យដំណេកវិញ គេបានឃើញជនទាំងនោះទាំងក្មេង ទាំងចាស់ ដេកនៅតាមចិញ្ចើមថ្នល់រង្គោក(ដូចជាកំណាត់ឈើឬកំណាត់ទុសដែលគេបោះចោលលើចិញ្ចើមថ្នល់) ឬនៅតាមសាលាវត្ត គ្មានខ្នើយកន្ទេល មុង ឬសំពត់ដណ្ដប់សម្រាប់ជួយការពារសេចក្ដីសុខក្នុងពេលដេកនោះសោះឡើយ ។

រូបភាពដែលដិតដាមក្នុងដួងចិត្ត ហើយបំភ្លេចទៅមិនបាននោះ គឺរូបភាពរបស់កុមារអនាថា ៣ នាក់ជាបងប្អូនរួមឧទរមួយ លក់ទាំងអង្គុយមានក្បាលកកក់ៗទៅរកគ្នា មានកន្ទេលចាស់មួយដណ្ដប់រួមគ្នាទាំង ៣ នាក់ ខ្នងកុមារបងបង្អស់ផ្អែកទៅនឹងជញ្ជាំងផ្ទះថ្មក្បែរថ្នល់ខ្ញុំបានជួបនឹងហេតុនេះនៅពេលព្រលឹមស្រាងៗ ប្រហែលជាម៉ោង៥កន្លះ ក្មេង៣នាក់នោះដេកស្ទើរភ្ញាក់ស្ទើរលក់ ឃើញដៃទះបោសញយ ៗ ដែលត្រូវ

បាណកជាតិ មានស្រមោចនឹងមូសជាដើម ដែលចូលទៅផ្ញាក់យកឈាមកំសត់របស់ក្មេងទាំងនោះ ឯធាតុអាកាសវិញក៏បញ្ចេញសីតធាតុយ៉ាងពេញទំហឹង ធ្វើឲ្យក្មេងទាំង ៣ នាក់នោះយកខ្លួនទឹងខ្លួនទល់គ្នា ដើម្បីទប់ទល់នឹងអាកាសត្រជាក់តែប្រសិនណាបើក្មេងទាំងនោះផ្តេកខ្លួនឲ្យរាបទៅនឹងប្រឹថពីទៅ ក៏គង់មិនបានទទួលសេចក្តីកក់ក្តៅអ៊ុនៗ ដូចជាអង្គុយលក់នោះទេ ព្រោះសំពត់នោះ តូចពេកមិនអាចបិទបាំងការពារត្រជាក់រងានោះបាន ដូចជាអង្គុយប្រជ្រៀតគ្នាឡើយ ហើយថែមទាំងកន្លែងនោះគ្មានអ្វីប្រក់ពីលើសោះ ជាឱកាសឲ្យទឹកសន្សើមធ្លាក់ចុះមកទទឹកខ្លួនជោក ដូចជាយកទឹកទៅចាក់ពីលើ ថែមទាំងពេលនោះអាកាសក៏ត្រជាក់ណាស់ផង, សូម្បីតែរូបខ្ញុំដែលមានសំលៀកបំពាក់គ្រាន់ការពាររងាស្ទើរតែទ្រាំនឹងអាកាសត្រជាក់នោះពុំបាន ចំណង់បើគ្នាគ្មានអ្វីការពាររងាសោះ តើក្មេងទាំងនោះ នឹងទទួលការគំរាមកំហែងពីអាកាសត្រជាក់នោះយ៉ាងណាទៅ? និមិត្តរូបដែលនាំឲ្យកើតសំវេគចិត្តដូចបានពណ៌នាមកហើយនេះ នាំឲ្យខ្ញុំយល់វែងទៅទៀតថា នឹងមិនមានតែប៉ុណ្ណោះទេ គង់នៅមានទៀតជាច្រើន ទាំងលោក-អ្នកក៏គង់ធ្លាប់បានជួបប្រទះឃើញខ្លះមិនខាននូវសំវេគសញ្ញាបែបខាងលើនេះ ។ ពួកក្មេងដែលបានរៀបរាប់មកទាំងនេះ គឺក្មេងអនាថាឥតទីពឹងផ្អែកសោះ បើទុកណាជាឪពុកម្តាយដែលចាត់ថាជាទីពឹងរបស់ក្មេងនោះៗ មាន ក៏ហាក់ដូចជាគ្មានដែរ ព្រោះឪពុកម្តាយសុទ្ធតែជាមនុស្សក្រីក្រលំបាក រកទទួលទានបានត្រឹមខ្វះល្ងាច ហើយគ្មានឱកាសណា ដែលល្មមនឹងជួយឧបត្ថម្ភគាំទ្រចិញ្ចឹមរក្សាបុត្រឲ្យបានពេញលក្ខណៈទេ កាលបើដូច្នេះ កុមារទាំងនោះ ក៏នឹងធ្លាក់ទៅក្នុងអន្លង់នៃសេចក្តីវិនាសកាន់តែជ្រៅក្រៃលែងណាស់ទៅទៀត គឺនឹងជួបប្រទះនូវទារុណកម្មផ្សេងៗ មានការសង្កត់សង្កិនឬបង្គាប់បញ្ជារបស់បរជនណាមួយឲ្យធ្វើការធ្ងន់ៗ ជាដើមក៏សឹងបាន. ។

បើប្រសិនជាក្មេងនោះ កំព្រាដោយគ្មានទាំងម្តាយទាំងឪពុកសេចក្តីវេទនាក្នុងការចិញ្ចឹមជីវិត, លំនៅ, សំលៀកបំពាក់, ថ្នាំការពាររោគ នឹងរឹតតែមានទម្ងន់យ៉ាងក្រៃលែងណាស់ ទៅទៀត ។

រឿងកុមារអនាថានេះនឹងទៅជាប្រស្នាមួយដែលជាប់ទាក់ទងនឹងវឌ្ឍនធម៌របស់ប្រទេស ព្រោះហាយនភាពនឹងកើតឡើងដល់កុមារកំព្រា បែបនេះជាប្រាកដ ហើយក្នុងជីវភាពតទៅអនាគត កុមារទាំងនោះនឹងដេកត្រាំក្នុងចរិយាដ៏ទន់ទាប ដែលចាត់ជាអបាយមុខរបស់ជនពាល ដូចតទៅនេះគឺ :

១– ទៅជាអ្នកលេងស៊ីផឹកប្រឡៃប្រះកាគ្មានទីពឹង ;

២– ទៅជាមនុស្សព្រហើនកោងកាច ប្រព្រឹត្តចោរកម្មលួចឆក់ឆក់ដណ្តើមទ្រព្យសម្បត្តិអ្នកដទៃ ;

៣ - ទៅជាអ្នកលេងល្បែងស៊ីសងគ្រប់ប្រភេទ ;

៤– ទៅជាមនុស្សល្ងង់មិនស្គាល់ហេតុខុសត្រូវ;

៥– ទៅជាមនុស្សក្បាលរឹងចិត្តអាក្រក់ មិនចេះស្រឡាញ់ជាតិមាតុភូមិរបស់ខ្លួន;

៦– ទៅជាមនុស្សប្រព្រឹត្តទុច្ចរិត នាំបង្កបង្កើតវិនាសកម្មគ្រប់យ៉ាង តាមទំនើងចិត្តរបស់ខ្លួន ដែលជាហេតុនាំឲ្យខូចខាតដល់នីតិច្បាប់សម្រាប់ប្រទេស និង ជាឧបសគ្គយ៉ាងធំចំពោះរដ្ឋាភិបាល ក្នុងការរៀបចំប្រទេសជាតិ ។

(នៅមានត)

# ចៅស្នែងទន្សាយ

## ធ្វើដំណើរព័ទ្ធពិភពលោកជាលើកដំបូង



ប្រទេសនេប៉ាល

ចៅស្នែងទន្សាយជាបុត្រនៃអ្នកចម្ការម្នាក់ នៅភូមិចម្ការសំរោង ឃុំស្វាយប៉ោ ខេត្តបាត់ដំបង, បិតានាម "ពុកមាតគង់គក់; មាតានាមនាងចង្កេះរួញ ។ លោកពុកមាតគង់គក់ ទឹងនាងចង្កេះរួញមានកូនប្រុសបីនាក់, កូនស្រីពីរនាក់ ។ បណ្ដាកូនប្រុសបីនាក់នោះចៅស្នែងទន្សាយជាបុត្រពៅ បានរៀបការជាមួយនឹងនារីម្នាក់នាមនាងស្អាត ជាភរិយា បានតាំងហាងមួយលក់គ្រឿងទេសមានម្រេច,ខ្ទឹមជាដើម ។ ឆ្នាំនេះចៅស្នែងទន្សាយចំណេញម្រេចដែលបានដឹកនាំងពីខេត្តកំពតមកចំនួន៥០០០គោន គិតជាប្រាក់១៥០.០០០រ.០០ ។

មានមួយថ្ងៃ ក្នុងគិម្ហរដូវ ចៅស្នែងទន្សាយប្រឹក្សាជាមួយនឹងភរិយាថា ឆ្នាំនេះយើងមានភោគទ្រព្យគ្រាន់បើល្មមនឹងទៅមើលនានាប្រទេស មានប្រទេសនេប៉ាលជាដើម ។ ភរិយាចៅស្នែងទន្សាយ ក៏បានស្រុះគំនិតក្នុងការប្រឹក្សាគ្នាបានរៀបសំលៀកបំពាក់នឹងប្រដាប់ផ្សេងខ្លះ គ្រាន់ជាជំនួយដល់ការធ្វើដំណើរនៃស្វាមីខ្លួន កាលបើភរិយាបំពេញកិច្ចរៀបចំហើយ ចៅស្នែងទន្សាយក៏ចេញដំណើរមករាជធានីភ្នំពេញ បានជួលអាកាសយានជិះទៅក្រុងត្រៃពនគរ, រួចបានបន្តដំណើរទៅទីក្រុងកល់កុត្តាតម្រង់ទៅក្រុង កាត់ត្មណ្ឌូ (ប្រទេសនេប៉ាល់) តែម្ដង ។

ប្រទេសនេប៉ាល់ ជាប្រទេសមួយខ្វះគមនាគមន៍សម្រាប់ធ្វើចេញចូលកាន់ប្រទេសជិតខាង ជាយូរលង់ហើយ ឥឡូវគមនាគមន៍ ដែលទើបនឹងបានស្ថាបនាពុំទាន់មានគ្រប់គ្រាន់នៅឡើយ ចំពោះការធ្វើកាត់ព្រៃដែនប្តូរខាងក្នុងប្រទេស; គេឃើញមានអ្នកទេសចរជាច្រើនចេញចូលមកមើលប្រាសាទបុរាណ ព្រមទាំងផ្លូវខាងពាណិជ្ជកម្មផង" ។

ចៅស្នែងទន្សាយបានចុះពីអាកាសយាន ហើយ

ឡើងលើរថយន្តឈ្នួលសំដៅទៅកាន់ទីផ្សារ គាត់បានសូមសំណាក់នៅគេហដ្ឋានគាព្រិនបាល ទើបបានសេចក្ដីរៀបរាប់របស់គាត់ជាដំបូង ដោយការសួររបស់ចៅស្នងខ្សាយដូចតទៅថា:

កាលដើមប្រទេសនេះជនបរទេសមិនអាចចូលទៅទីម្នាងនៃក្នុងៗ នោះបានទេ ដោយមានបញ្ញត្តិពីរដ្ឋមន្ត្រីហាមមិនឲ្យជនបរទេសទៅមកបាន ។ តាំងពីសម័យមជ្ឈិមយុគ (១) មិនមានជនណាទៅមកប្រទេសនេះសោះឡើយ ។ ទើបតែមកក្នុង ១៨ខែមុននេះមានការបដិវត្តន៍ប្រទេស(២) ធ្វើឲ្យប្រទេសនេប៉ាល់មានសភាពទៅតាមសម័យនិយមជាច្រើន ដោយការបដិវត្តន៍នៃអ្នកអន្តោប្រវេស គេឃើញមានបំពង់ទឹកដែលទើបបង្កើតឡើងតាមសម័យទំនើបជាច្រើន, មានគ្រឿងអគ្គិសនីទីងរថយន្តចេញចូលខ្វាត់ខ្វែង ដល់ព្រះបរមរាជវាំងនៃទីក្រុងកត់តណ្ឌូ ដោយមានរដ្ឋមន្ត្រីស្រឡាញ់វឌ្ឍនភាពរបស់ប្រទេស បានប្រែទៅតាមអារ្យធម៌នៃប្រទេសសេរីទាំងឡាយ ជាអ្នកផ្ដើមគំនិតឡើង ។

បើតាមពិនិត្យទៅផ្លូវទាំងអស់នៅក្នុងប្រទេសនេះមានប្រហែល ៥ គីឡូម៉ែត្រ ; មានផ្លូវ មួយដែលរថយន្តបរបានដោយលំបាកចេញពីព្រះរាជធានី ទៅកាន់ជ្រោះភ្នំកត់តណ្ឌូ ចំនួនជា ១៥ គីឡូម៉ែត្រក្នុងទិសមួយ ។ ក្រៅពីនេះមានសុទ្ធតែផ្លូវដើរដែលឆ្លងពីជ្រោះភ្នំមួយទៅជ្រោះភ្នំមួយ ឬទៅតាមច្រកភ្នំ ។ ប្រទេសនេះមានទំហំ ១៤០.០០០ គីឡូម៉ែត្រ ក្រឡា ។

គមនាគមន៍(១) ប្រទេសឥណ្ឌា នឹងនេប៉ាល់ ពីមុនគេឃើញមានតែផ្លូវលំមួយ នៅប្រទេសដើរភ្នំមានតែអ្នកបើរដើរ ឬអ្នកជិះសេះទើបទៅមកបាន ។ ប៉ុន្មានឆ្នាំក្រោយនេះមានផែនការណ៍(២) មួយថ្មីសម្រាប់ធ្វើឲ្យប្រទេសនេះមាន គមនាគមន៍ទាក់ទងនឹងសាមន្តប្រទេស(៣), ញ៉ាំងជាសាស្ត្រកសិកម្ម(៤) នឹងវិធីរកធនធានខាងធម្មជាតិនឹងវឌ្ឍនភាព ខាងពាណិជ្ជកម្ម ខ្សោហកម្មឲ្យបានចំរើនក្នុងប្រទេស ។ មានកើត



គមនាគមន៍ខាងផ្លូវអាកាស ជាដំបូងដែលធ្វើដំណើរក្នុងមួយសប្ដាហៈ(៥) ច្រាំដងពីទីក្រុងកត់តណ្ឌូ

(១). សម័យមជ្ឈិមយុគ គឺសម័យកណ្ដាល សម័យដែលមនុស្សនៅកាន់បុរាណ, សម័យដែលវិជ្ជាមិនទាន់មានបរិបូណ៌នៅក្នុងពិភពលោក ។ (២) បដិវត្តន៍ បះបោរតាមការសិទ្ធិផ្សេង ៗ ។

(១) ការប្រាស្រ័យទៅវិញ-មក ។ (២) ផែនរឿង, ផែនទីដែលគិតរៀបចំប្រទេស ។ (៣) ប្រទេស ជិតខាង ។ (៤) វិធី ធ្វើម៉ាស៊ីនទឹក ឬដាំទឹកសម្រាប់ស្រោចស្រែចម្ការ ។(៥) មួយអាទិត្យ ។

ទៅទីក្រុងប៉ាត់ណាឬបត្នៈ (ប្រទេសឥណ្ឌាខាងត្បូង) ។

មានផ្លូវលំបួនកាត់ទងគ្នានៃព្រះរាជធានី នឹងខេត្តក្រៅឆ្ងាយ ៗ ។ គេបានផ្តើមធ្វើផ្លូវមួយចម្ងាយមួយរយគីឡូម៉ែត្រ ទៅដល់ទីក្រុងកាប៊ូល ព្រំដែន នៃប្រទេសឥណ្ឌា ដើម្បីជាកិច្ចទាក់ទងគ្នាជាបឋមរវាងប្រទេសនឹងទីក្រុង មានផ្លូវមួយទៀត គេរៀបនឹងសាងឡើងនៅអនាគតឆាប់ ៗ នេះឆ្ពោះទៅដល់ជ្រោះក្នុករៈប្រទេសនេប៉ាល់ខាងលិច ទីនោះមានអាការយ៉ាងស្ងាត់មានតិណជាតិដុះខៀវស្រងាត់មានអាកាស ត្រជាក់ល្មមនឹងបឹងធំនៅប្រចក្ខ អន្នាបុរនៈដែលមានកំពស់ ៩០០០ ម៉ែត្រ’ អាចចាត់ជារមណីយស្ថានកំសាន្តចិត្តសម្រាប់រដូវក្តៅ ចំពោះជនជាតិឥណ្ឌានៅបិហារ ដែលជាពលប្រាសចាកផលានុផល ព្រមទាំងពួកទេសចរបរជាតិ[១] ។

គេបានស្វែងរកធនធានក្នុងស្រុកមានសហគ្រាស[២] នៃត្បូងថ្ម, ត្បូងមីកា[៣], លោហធាតុកូបាល់ត (cobalt)[៤] ក្តារឈ្នួន មាសនឹងប្រេងកាត.... ។

តាព្រឹទ្ធបាលគាត់ចង់សំរាកកម្លាំងបន្តិចទើបប្រាប់ទៅស្នងទន្សាយថា, ចាំពិសារបាយរួច ខ្ញុំនឹងជំរាបរឿងរ៉ាវខ្លះដែលទាក់ទងដោយប្រវត្តិសាស្ត្រ ជូនលោកស្តាប់តទៅទៀត ។

ក្នុងពេលបរិភោគអាហារ, តាព្រឹទ្ធបាលសួរទៅចៅ "ស្នងទន្សាយ" ថា: "ចៅមកពីប្រទេសណា? ចៅស្នងទន្សាយឆ្លើយតាព្រឹទ្ធបាលថា: "លោកតា, ខ្ញុំមកពីប្រទេសកម្ពុជាឬប្រទេសខ្មែរ, ជាប្រទេសដែលមានប្រាសាទបុរាណល្បីល្បាញជាងគេ; លោកតាប្រហែលជាធ្លាប់ជ្រាបកិត្តិសព្ទប្រាសាទអង្គរវត្ត, អង្គរធំ ដែលពួកទេសចរបរជាតិជាច្រើនបានទៅទស្សនារាល់ឆ្នាំ ជាប្រាសាទដែលគេចាត់ទុកជាអច្ឆរិយវត្ថុនា-សកលជម្ពូទ្វីប ។ ប្រទេសនោះពីសម័យបុរាណ, ក្នុងរជ្ជកាលសន្តតិវង្ស "វរ្ម័ន" មានកិត្តិសព្ទល្បីល្បាញជាមហាប្រទេសមួយប្រកបដោយវិទ្ធានុភាព ស្ថិតនៅអាស៊ីប៉ែកអគ្នេយ៍ ។

ក៉យ-ប៊ុត

(មានត)

---

(១) ទេសចរ = អ្នកទៅមើលប្រាសាទបុរាណ ។ (២) សហគ្រាស = ទីកន្លែង ដែលគេស្វែងរកធនធានមានអណ្តូងរ៉ែ, ត្បូង, ជាដើម (៣) មីកា = ថ្មត្បូងមានដាសខ្ទិក, ស្រកាភ្លឺ ៗ ។ (៤) លោហធាតុពណ៌សក្រហមរឹងស្រួយឆាប់បែកបាក់គេសម្រាប់យកទៅធ្វើល័ក្ខ ។

## ព័ត៌មានគួរដឹងខ្លះ គួរគិតខ្លះ
## អាមេរិក នឹងឥណ្ឌូចិន

កាលពីថ្ងៃទី ១០ កុម្ភៈ ១៩៥៤ ប្រធានាធិបតីអៃសិនហូវ័រ បានឲ្យសម្ភាសន៍ ដល់ពួកអ្នកកាសែតថាសហរដ្ឋអាមេរិកនឹងព្យាយាមចៀសវាងមិនចូលធ្វើអន្តរាគមន៍ (ការជ្រៀតជ្រែក) ក្នុងសង្គ្រាមឥណ្ឌូចិន

យ៉ាងពិតប្រាកដ ។

គេចាំបានថា ការដែលលោកប្រធានាធិបតីបានថ្លែងដូច្នេះ មកពីមានសមាជិកនៃសភាជាន់ខ្ពស់(ព្រឹទ្ធសភា) និងសភាតំណាងរាស្ត្រច្រើនរូបបន្ទោសលោកថា ធ្វើនយោបាយផ្សងព្រេងដោយហ៊ានបញ្ជូនទាហានជើងអាកាសយាន និងអ្នកតិកនិកទៅអនុគ្រោះសេចក្តីណែនាំដល់ទាហានបារាំងសែសឲ្យចេះប្រើអាវុធសម័យថ្មីដែលអាមេរិកបញ្ជូនទៅ ។ មួយទៀតពួកសមាជិកសភាទាំងពីរបានធ្វើការរិះគន់លោក យ៉ាងធ្ងន់ "នយោបាយដែលលោកធ្វើទៅ គឺជាការធ្វើដោយគិតភ្លូងមិនដឹងដល់ហេតុការណ៍" ។

លោកប្រធានាធិបតីមានសេចក្តីតូចចិត្តចំពោះសំដីនេះពន់ពេក លោកបានបញ្ជាក់ប្រាប់អ្នកកាសែតថា បញ្ជូនអ្នកតិកនិក និងទាហានជើងទាំងនេះទៅកាន់ឥណ្ឌូចិននោះ គឺឲ្យទៅក្នុងឋានៈជាកងការស៊ីវិល មិនមានការពាក់ព័ន្ធនឹងចម្បាំងទេ ហើយអ្នកទាំងនោះនឹងត្រឡប់មកកាន់សហរដ្ឋវិញនៅពេលឆាប់ ៗ នេះ ក្រោយដែលបានប្រតិបត្តិនាទីរបស់ខ្លួន, និងការប្រគល់យុទ្ធោបករណ៍ទាំងនោះរួចហើយ ។

តាមលោកប្រធានាធិបតីបានអះអាងថាសហរដ្ឋអាមេរិកមិនចូលធ្វើអន្តរាគមន៍ ក្នុងសង្គ្រាមនៅឥណ្ឌូចិននេះ មានហេតុផលគួរជឿបានថា សហរដ្ឋអាមេរិកពិតជាធ្វើដូច្នេះមែន ។ យើងយល់ថាសហរដ្ឋមិនពាក់ព័ន្ធ នឹងសង្គ្រាមឥណ្ឌូចិន ក្រៅពីត្រឹមតែបញ្ជូនអាវុធ និងឲ្យសេចក្តីអនុគ្រោះដល់ទ័ព សហភាពបារាំងសែសមួយអន្លើសមាគតរដ្ឋទាំងបីដើម្បីបង្ក្រាបវៀតមិញ ប៉ុណ្ណោះឡើយ ។

សព្វថ្ងៃនេះកងទ័ពសហភាពបារាំងនៅឥណ្ឌូចិនដែលមានកំឡាំងទាហានមកពីក្រៅឥណ្ឌូចិន ផងមានកងទ័ពនៅប្រទេសឥណ្ឌូចិនផង រួមទៅមិនតិចជាង ៤០០.០០០នាក់ ។ អ្នកទាំងនេះបានធ្វើសង្គ្រាមនឹងវៀតមិញចំនួន ៧ ឆ្នាំហើយ ដោយបានអាវុធមួយផ្នែកអំពីសហរដ្ឋអាមេរិក និងអាវុធដែលកសាងនៅក្នុងសហរដ្ឋ ។ សព្វថ្ងៃបរិមាណនឹងចំនួននៃអាវុធចេះតែកើនឡើងៗ ។

គេដឹងច្បាស់ថា ជំនួយរបស់សហរដ្ឋអាមេរិកបានកើនឡើងស្មើនឹងពាក់កណ្តាលនៃដើមទុន បារាំងសែសបានចំណាយក្នុងសង្គ្រាម ដែលពុំដឹងជាចប់ថ្ងៃណានោះ ។ ក្នុងឆ្នាំនេះសហរដ្ឋអាមេរិកបានតាំងថវិកាជួយបារាំងសែស ធ្វើសង្គ្រាម នៅឥណ្ឌូចិនចំនួន ៥០០.០០០.០០០. ដុល្លារ លុះតមកបានដឹងថា បារាំងសែសអន់ជាងវៀតមិញ ក៏ព្រមព្រៀងគ្នាជួយទៀតចំនួន ៣៥០.០០០.០០០ ដុល្លារ ។ គិតទៅចំនួនដែលជួយ បូករួមទាំងអស់ ៨៥០.០០០.០០០ ដុល្លារ ។

គេនាំគ្នាស្មានថា បើស្ថានការណ៍ក្នុងឥណ្ឌូចិនមិនបានស្រួលបួលតទៅទៀត ឬមួយចេះតែទ្រុឌទ្រោមទៅ មុខជាសហរដ្ឋអាមេរិកនឹងជួយទំនុកបំរុង

ទ្វេឡើង ដើម្បីឲ្យមានសមត្ថភាព តាមសេចក្តីត្រូវការរបស់កងទ័ពសហភាពបារាំងសែស និងតាមសេចក្តីត្រូវការនៃសមាគមរដ្ឋទាំង ៣ ដែលកំពុងខ្វះខ្វែងចាត់តាំងកងទ័ពរបស់ខ្លួន ។

អ្នកផងធ្លាប់ពោលមកហើយថា ការទាក់ទងរបស់សហរដ្ឋអាមេរិកក្នុងសង្គ្រាមនៅឥណ្ឌូចិននោះ ធ្វើឲ្យអាមេរិកស្ថិតនៅក្នុងឋានៈ ជាគូចម្បាំង តែមិនចូលប្រឡូកពេញមុខដែលភាសាបារាំងហៅថា **Non Belligerant,**

គេចាំបានថាប្រសាសន៍របស់លោកប្រធានាធិបតីអែសិនហូវ៉ែរកាលថ្ងៃពីថ្ងៃទី១០កុម្ភៈក៏បានបញ្ជាក់ឲ្យឃើញថាសហរដ្ឋអាមេរិក មិនប្រាថ្នានឹងប្រែប្រួលឋានៈជា **Non Belligerant** ទៅជាគូសង្គ្រាមប្រឡូក **(Belligerant)** ទៅវិញឡើយ ។ ម្យ៉ាងទៀតសង្គ្រាមនៅឥណ្ឌូចិន បើតាមទស្សនៈរបស់លោកវិលសុនរដ្ឋមន្ត្រីការពារប្រទេសអាមេរិកបានអះអាងថា ទោះបីដូចម្តេចក៏ដោយ ក្នុងខណៈនេះនៅពុំទាន់មានហេតុផលដែលគួរជឿបានថាឥណ្ឌូចិន នឹងក្លាយទៅជាកូរ៉េទេ ។

សេចក្តីថ្លែងរបស់ប្រធានាធិបតី និងទស្សនៈរបស់លោកវិលសុនជាមូលដ្ឋាននៃនយោបាយរបស់សហរដ្ឋអាមេរិក ដែលថាមិនចូលធ្វើអន្តរាគមន៍ក្នុងសង្គ្រាមឥណ្ឌូចិន ដរាបណាសង្គ្រាមឥណ្ឌូចិននៅមិនទាន់ប្រែសភាពជាសង្គ្រាមដូចកូរ៉េ ដែលត្រូវប្រើកំឡាំងមនុស្ស ។ បើថាសង្គ្រាមនេះប្រែសភាពនឹងពង្រីកអាណាខេត្តធំទូលាយដរាបដល់ទៅជាសង្គ្រាមនៅកូរ៉េ ពេលណា ពេលនោះនយោបាយអាមេរិកមុខជាប្រែប្រួលទៅបានជាពិតប្រាកដ ដើម្បីឲ្យស្របទៅតាមស្ថានការណ៍ដែលកើតឡើង ហើយនៅខណៈនោះទាំងលោកប្រធានាធិបតីទាំងលោកវិលសុន ប្រហែលជាធ្វើសេចក្តីថ្លែងអ្វីមួយទៀតមិនដូចកាលថ្ងៃនៅថ្ងៃទី ១០ កុម្ភៈជាប្រាកដ ។

តាមដែលសហរដ្ឋអាមេរិក នៅរឹងឥរិយាបថមិនចូលទាក់ទង ជ្រៀតជ្រែកក្នុងសង្គ្រាមនៅឥណ្ឌូចិនឲ្យហួសកំរិត ត្រឹមតែបញ្ជូនយុទ្ធោបករណ៍និងអ្នកតិក-និកមកជួយនោះ, ព្រោះត្រូវការជៀសវាងនឹងដឹកនាំឲ្យចិនកុម្មុយនិស្តបញ្ជូនទាហានចូលមកក្នុងឥណ្ឌូចិន ដើម្បីជួយវៀតមិញដោយបើកចំហ ដូចធ្លាប់ធ្វើមកហើយកាលសង្គ្រាមរវាងកូរ៉េនិងកូរ៉េ ។

គេដឹងច្បាស់ថា បើសហរដ្ឋអាមេរិកចបេសចូលមកជ្រៀតជ្រែកនឹងសង្គ្រាមនៅឥណ្ឌូចិនដោយការបញ្ជូនទាហានឲ្យមកជួយច្បាំងបារាំងសែសដោយចំពោះហើយ, ចិនកុម្មុយនិស្ត នឹងអាងហេតុផលថាអំពើរបស់អាមេរិកគឺគំរាមលើផលប្រយោជន៍របស់ខ្លួន នឹងគំរាមសេចក្តីនិរភ័យនៃជនជាតិខ្លួនដែលនៅឥណ្ឌូ-ចិន ហើយគេមុខតែនឹងបញ្ជូនពួកយោធាគេឲ្យចូលមកជួយវៀតមិញជាប្រាកដ ។ អ្នកសង្កេតការណ៍ខ្លះយល់ថាបើហេតុដូច្នេះកើតឡើងមែនគឺត្រូវចំនឹង

ពាក្យលោកអ្នកប្រាជ្ញប្រវត្តិសាស្ត្រម្នាក់ថា “ គ្មានអ្វីថ្មីក្នុងពិភពលោកនេះទេ ស្ថានការណ៍បច្ចុប្បន្ន គឺជាស្ថានការណ៍ដែលធ្លាប់មានមកពីអតីត ”

---

## ញញឹកក្នុងពោះ

### អ្នកថូស់ចង្កេះនឹងត្រែដេញខ្មោច

នាយកេមថូស់ចង្កេះ, ដើរដើរទៅណាមកណាម្តងៗ ដំណើររសុតស្ទើរវិស័យដូចតុក្កតាល្ខោន ៗ គាត់រកថ្នាំសង្កូវផ្សេងៗ មកដាក់មិនត្រូវសោះ, រកគេមកឲ្យច្របាច់សរសៃឲ្យ ក៏រឹតតែឈឺលើសដើមទៅទៀត ដកបទាល់តែងើបមិនរួច នៅដេកថ្ងូរតែក្នុងខ្ទមៗ ទើបឯនាងកុនជាប្រពន្ធគិតថា “ថូស់ចង្កេះនេះមើលទៅមិនមែនរោគធម្មតាទេ ប្រាកដជាមានខ្មោចព្រាយចូលមកបៀតបៀននៅក្នុងខ្លួនប្តីអញហើយ បានជាចេះតែរឹតខ្លាំងឡើងៗ ហើយសំឡេងថ្ងូរបែបប្លែកដូចជាសំឡេងខ្មោច, រឿងនេះអញនឹងបណ្តោយទុកឲ្យយូរតទៅទៀតពុំបាន, គោងតែរកគ្រូមកមើលឲ្យចាប់ដេញខ្មោចចេញ” គិតយ៉ាងនេះហើយ នាងកុនក៏កាន់ទៀន-ធូបម្លូស្លាចូលទៅរកតាកែលដែលនៅផ្ទះខាងចុងភូមិ ជំរាបគាត់តាមដំណើរសព្វគ្រប់ហើយ សុំអញ្ជើញឲ្យមកដេញខ្មោចព្រាយថូស់ចង្កេះប្តីខ្លួន ។ តាកែលទាញថង់យាមដំពេញដោយថ្នាំសង្កូវសព្វមុខ ប្រញាប់ប្រញាល់ដើរតាមក្រោយនាងកុន ។ ទៅដល់ហើយ, តាកែលយកខ្សែអម្បោះមកផ្លុំស្រូតបញ្ចុះមន្តអាគម តាមទំនៀមហើយក៏ចងម្រាមដៃម្រាមជើងនាយកេម រួចគាត់គំហកគំហែងសួរថា:— ឯងឈ្មោះអី?

នាយកេម:– បាទ,ខ្ញុំឈ្មោះកេម ។

តាកែល:– ទេ,កុំបន្លំ ប្រាប់ឲ្យត្រង់មក ។

នាយកេម:- បាទ, ឥតបន្លំទេ ត្រង់អស់ប៉ុណ្ណឹងហើយ, ឈ្មោះកេមនេះគឺខ្មោចយាយកូ ចាំជូនម៉ប គាត់បានដាក់ឲ្យមកតាំងពីខ្ញុំទើបនឹងកើតហើយម៉្លេះ ៗ

តាកែល:- ឯងមកពីណា ?

នាយកេម:- បាទ, ខ្ញុំឥតមកពីណាទេ គឺនៅនឹងផ្ទះខ្ញុំនេះតែម្តង ៗ

តាកែល:- ឯងចង់បានអី បានជាមកបៀត-បៀនគេយ៉ាងនេះ?

នាយកេម:- (ថ្ងូរបណ្តើរ) បាទ, ឥតចង់បានអី-ទេ, ចង់បានតែឲ្យជាថូស់ចង្កេះប៉ុណ្ណោះ ៗ

តាកែល:- ឯងកុំពូកែពេក! ប្រយ័ត្នអញចងឯងឲ្យឆាប់នៅទីនេះ! មើល! យើងសម្រេចគ្នាឲ្យហើយទៅតើឯងចេញឬមិនចេញ?

នាយកេម:- បាទ, មិនដឹងជាចេញទៅឯណា, បានទេ, បើមនុស្សឈឺរកតែឆាកខ្លួនមិនរួចផង ៗ

តាកែល:- ដេះ! ខ្មោចនេះឆ្លាតមែន! នៅតែ-ធ្មើយបន្ទំទៀត!

នាយកេម:- បាទទេ! មានខ្មោចឯណា មនុស្សទេតើ ៗ

នាងកុន៖- លោកតា! សុំលោកតាអាណិតកិនកុំហែងឲ្យមែនទែនមើលទៅខ្លាចនេះគួរតែមោម្នះខ្លាំងចំណាប់ហើយ ។

នាយគេម៖- (ទឹងញ៉ូមាត់) មិនដែលមាន, មេបារហិនហោច! គ្នាថ្ពះចង្កេះឯណេះឈើស្មើរតែទឹងដាច់ខ្យល់ទៅគិតដេញខ្លាចឯណាទៅវិញមានតែខ្លាចម៉ែហែងឯង ។

តាកែល៖— (មើលមុខនាងកុន) នាងស្ដាប់ចុះ! ញុះទេ! អាខ្លាចនេះចេញស្នៀតញីកមែន!

នាយគេម៖ (ទឹងខ្លាំងណាស់) ចុះម៉ឹកកុន ហើយទឹងអាតារំបល់កាច់នេះ វាឆ្កួតទេឬ? នុះទេព្ដាអើយ! អាណិតឲ្យតែខ្ញុំត្រូវដេរគ្រោតគ្រួច, អ្នកពលគ្នានេះមុខជារកប្រែកលោតមិនទាន់ស្លៀវហ្នឹងហើយ ។

តាកែល៖— អៃយ៉ា! អានេះចង់តដៃហើយរឺ! បើយ៉ាងនេះតើយើងគិតលេងផ្លូវណាទៀត?

នាងកុន៖ — ចា៎ះ ស្រេចតែលោកតាធ្លាប់ស្រាប់ហើយ ។

តាកែល៖ — តាំងពីចេះធ្វើគ្រូមក តាមិនដែលប្រទះខ្លាចណារបុឹងរឹងរូសដល់ម្ល៉ឹងសោះ បើដូច្នោះ, នាងឯងឲ្យរំពាត់ ១ មកតាផាប់ រកអាជុនធំចៅបន្តិចមក តាលេងអ្នកនេះម្ដងមើល ។

នាងកុនចុះទៅក្រោមខ្ទមពាញបានដើ្ដ ១ កំណាត់ ប្រវែងប្រហែល១ម៉ែត្រ យកមកឲ្យតាកែលៗបានរំពាត់ដល់ដៃហើយក៏ឡើងឈរឡើង តាំងវាយវាត់នាយគេមជាច្រើនរំពាត់ យ៉ាងអស់ទំហឹងដៃ ហើយគម្រាមផងថា៖ អាឯងខ្លាចអញឬមិនខ្លាច?

នាយគេមត្រូវរំពាត់ឈឺខ្លួនខ្លាំងណាស់អត់ទ្រាំពុំបាន ក៏តាំងប្រឡោតស្ទុះឡើងក្តាម លេងផ្ដាមតាកែលបាន ២ ដៃ ថែមកំពឹងគូថបាន ១ ជើងទៀត ធ្ញៀតទៅធាក់នាងកុនបាន ២ ជើងទៀតផង ។

តាកែលរត់បោលចង់យាម៉ នាងកុនរកដណ្ដើរមិនឃើញ, អ្នកទាំងពីរលោតពីលើខ្ទមយកតែប្រាសអាយុពល់ខ្លួនស្រែកឲ្យគេជួយផងថា ខ្លាចព្រាយតដៃហើយ ។

តាកែលទឹងនាងកុនទៅជួបគ្នាក្រៅរបងឆ្ងាយពីផ្ទះបន្តិច ហើយក៏សួរគ្នាទៅវិញទៅមកទាំងហត់ហោបៗផងថា៖ ម៉េចយើងមានត្រូវរបស់គេត្រង់ណាខ្លះទេ?

នាងកុន.— ខ្ញុំថ្ពះលោងម្ខាងទៅហើយ ព្រោះរកដណ្ដើរមិនឃើញ លេងតាមផ្លូវកាត់,

តាកែល. — គ្នាឯណេះជ្រុះបាត់ធ្មេញថ្គាមសំខាន់១គូទៅហើយ ព្រោះគេលេងឯងពីរដៃយ៉ាងដំណំ · យ៉ើះ! អាដែងខ្លាចបិសាចនេះបំជាមានបុទ្ធិអំណាចខ្លាំងមែន!

នាងកុន. — លោកតា! យើងចូលទៅម្ដងទៀតកុំឲ្យបាញ់ដៃវា!

តាកែល. - ទេៗនាង! នាងអញ្ជើញទៅចុះ បំណែកខ្ញុំសុំបញ្ចប់រៀងត្រឹមណឹងហើយ ព្រោះតាទុកធ្មេញខ្លះគ្រាន់ទឹងទំពាបាយ ។

ចំណែកនាយភេម, ដោយចំប្រើនស្ទុះក្រោកឡើង ចាំងទោសោ ទៅតដៃទឹងតាភែលនោះក៏ដូចជា គេកន្ត្រាក់សរសៃបានជាដូចដើមវិញហោង ។

---

# រឿងតុក្កតា របងា ទធិជាតិ

(ចំរេរ ប៉ូតុល)

**La Poupeé de Fromage**

លោករពិន្ទ្រណាថ តាគុរ អ្នករៀបរៀង

លោកក៉យ - ប៊ុក ប្រែមកជាភាសាខ្មែរ

## ព្រះអគ្គមហេសីទាំងពីរព្រះអង្គ

ពីអតីតកាល មានព្រះមហាក្សត្រមួយអង្គទ្រង់មាន ព្រះអគ្គមហេសី ពីរព្រះអង្គ ព្រះនាមសួ៉រានី និងឌួរានី (១) (ប្រហែលជាសុខរានី និង ទុក្ខរានី ?) ។



(១)នៅក្នុងរឿងព្រេងបឹងកាលី គេបានឃើញព្រះរាជនីទាំងពីរអង្គ ព្រះរាជនីទាំងនេះផាបដិម្ឃរា ប្រចាំៈ ព្រះរាជនីសុខ និងព្រះរាជនីទុក្ខ បានន័យថាៈ សំណាងល្អ សំណាងអាក្រក់ ។

ព្រះអគ្គមហេសី សុខរានីទ្រង់គង់ នៅក្នុងព្រះរាជដំណាក់មានជាន់ប្រាំពីរប្រកបដោយព្រះជ័យរីករាយ និងជាសុខភាព ដោយមានព្រះស្នំប្រាំពីររយនាក់ហោមរោមជុំវិញ ពល់តែចង់គេឃើញព្រះស្នំទាំងឡាយ ស្រោចទឹកគន្ធពិដោរលើព្រះបាទាដ៏ទន់ល្អក លាបលត ដោយពណ៌អលតៈ(១); សិតព្រះកេសក្អួតវែងមានបុប្ផាគ្រប់យ៉ាង ដែលបេះនៅឧទ្យានទាំងប្រាំពីរដាក់ពេញ កន្ត្រងប្រាំពីរសម្រាប់ថ្វាយព្រះអគ្គមហេសី សុខរានីផ្ទើះកម្រងព្រះនាង បើកទូខ្ចុបប្រាំពីរ ដែលមានមាសប្រាក់យកមកពីព្រះរាជឃ្លាំងមហារាជទាំងប្រាំពីរជាព្រះរាជ-ដង្វាយព្រះអគ្គមហេសី សុខរានី តុបតែងព្រះកាយនឹងគ្រឿងអលង្ការដ៏វិចិត្រ ។

ព្រះនាងសុខរានីគង់នៅដោយមានសេចក្ដីសុខជាសិរី, ទ្រង់មានព្រះរូបឆោមលោមពណ៌ល្អ, ព្រះមហាក្សត្រទ្រង់សព្វព្រះរាជហឫទ័យ ជាវិចិត្ររបស់ព្រះអង្គ ។

ចំណែកព្រះអគ្គមហេសីច្បងមាននាមថា ទុក្ខរានីតើមានព្រឹត្តិការណ៍បែបណាទៅ ?

ព្រះអគ្គមហេសីទុក្ខរានីទ្រង់គង់នៅ, ដោយប្រាសចាកសេចក្ដីស្នេហា និងសុខភាពព្រះមហាក្សត្រទ្រង់ឈ្មៀងព្រះនេត្រទៅកាន់

(១)អលតៈ គឺ ល័ក្ខក្រហមដែលគេលាបមេជើង, បាតជើង ធ្វើឲ្យស្បែកក្រហមឆ្អៅស្រស់ ។

ព្រះនាងប្រៀបដូចជាតុសបពុល? ទ្រង់បានព្រះរាជទានចំពោះព្រះនាង ត្រឹមតែគេហដ្ឋានមួយប៉ុណ្ណោះ ដែលបាក់បែកទ្រុឌទ្រោមជាច្រើនកន្លែង ព្រះនាងរស់នៅជាមួយទាសីម្នាក់ជូនហើយគងផងដែលព្រះរាជាទ្រង់ប្រទានដល់ព្រះនាង ចំពោះព្រះពស្ត្រព្រះនាងទៀតសោតក៏មានត្រឹមតែសារី(១) ចាស់ស្ទើររហែកអស់ទៅហើយ; ដើម្បីធ្វើចិត្តព្រះនាងឲ្យបានស្រួលក្នុងការជួបទ្រង់បានព្រះរាជទានខ្នុះ (២) រហែកកណ្តាចឲ្យព្រះនាងទៀត ។



ការយាងមកកាន់រាជដំណាក់គ្រាំគ្រានៃព្រះនាងទេវីចុងក្រោយនៃព្រះមហាក្សត្រ មានកំណត់មួយឆ្នាំម្ដងៗ ទ្រង់គង់តែមួយស្របក់ក្នុងដំណាក់ចាស់របស់ព្រះនាង នឹងមានព្រះបន្ទូលតែមួយព្រះឱស្ឋ ទ្រង់ក្រោកឡើងយាងចេញទៅ ..... ។

ឱកាសសល់តែនេះដប់ពីរខែ ( ១២ ខែ ) ព្រះរាជាទ្រង់គង់ជាសុខក្នុងរាជដំណាក់ព្រះនាងសុខរាទី ជាអគ្គមហេសីនៅក្នុងតរុណារ័យ ។

*
*   *

# នាវាទាំងប្រាំពីរ

មានកាលមួយថ្ងៃ, ព្រះមហាក្សត្រទ្រង់ត្រាស់បង្គាប់ទៅកាន់នាយករដ្ឋមន្ត្រី ដោយទ្រង់មានព្រះបន្ទូលថា:

“លោកនាយក ខ្ញុំចង់ទៅទស្សនាក្ងមិការផេតខាងទីនប្រទេសឆ្ងាយ, ត្រូវលោករៀបនាវាចាំងអស់ក្នុងពេលនេះ” ។

នាយករដ្ឋមន្ត្រីបានទទួលព្រះរាជឱង្ការរួចស្រេច, ក៏ចាត់ឲ្យលាបនាវាព្រមទាំងរចនាដោយក្បាច់ផ្សេងៗ ក្នុងពេលរៀបចំនាវាទាំងនោះគេត្រូវប្រើវេលា ៧ ខែ ទើបរួចស្រេច ។

នាវាប្រាំមួយសម្រាប់ព្រះរាជបរិវារ, នាវាលាបមាសមានព្រះបាកំរយោលជាមាសសម្រាប់ព្រះមហាក្សត្រគង់ហៅថា “ព្រះរាជនាវាសុវណ្ណជ័យ” ចាត់ទុកជានាវាទីប្រាំពីរ ។

ថ្ងៃមួយនាយករដ្ឋមន្ត្រីអញ្ជើញចូលក្រាបទូល

(១) សំពត់មានទំហុំ ៦ ម៉ែត្រសម្រាប់ធ្វើគ្រឿងសំលៀកបំពាក់នៃស្ត្រីហើយមានពួកស្ត្រីស្លៀកមានសភាពផ្សេងៗគ្នាទៅតាមខេត្ត ។

(២) ខ្នុះ = ភួយមួយបែបសម្រាប់ឲ្យស្រីនិទ្រាប់គឺគេយកសំពត់សារីចាស់ជាច្រើនដេរភ្ជាប់រួមគ្នា ហើយយកទៅជាតផាក្បាច់ល្អមើលមួយបែប ។

ព្រះមហាក្សត្រថា៖

"បពិត្រព្រះករុណាជាអម្ចាស់ជីវិតលើត្បូងនាក់ទាំងអស់បានប្រឹងប្រែងប្រសើរហើយ សូមព្រះតេជៈជ្រកលើត្បូងទ្រង់ជ្រាប" ។

ព្រះមហាក្សត្រ មានព្រះបន្ទូលទៅកាន់នាយករដ្ឋមន្ត្រីថា៖

ល្អហើយលោកនាយក, ខ្ញុំនឹងចេញដំណើរទៅថ្ងៃស្អែកនេះ ។

*
* *

## សេចក្ដីបំណងនៃព្រះនាងសុខវាទី

នៅខាងក្នុងព្រះរាជដំណាក់ ព្រះនាងសុខវាទី, គេឃើញព្រះនាងកំពុងគង់លើព្រះទែនបន្ទំ លាបលនដោយមាស; ព្រះស្នំប្រាំពីររូប ស្ថិតនៅគាល់ព្រះនាងបម្រើជាប្រក្រតី ។

ព្រះមហាក្សត្រទ្រង់យាងដំណើរទៅកាន់ព្រះរាជដំណាក់ព្រះនាងសុខវាទី, លុះយាងដល់ខាងមុខក្រឡាព្រះតំនាលមាស, ទ្រង់គង់នៅទីនោះ ហើយមានព្រះបន្ទូលទៅកាន់ព្រះនាងជាទីស្នេហាពេញព្រះទ័យថា៖

"ឱព្រះអគ្គមហេសី, បងនឹងទៅទស្សនាកម្មភាគជិតខាងនឹងប្រទេសឆ្ងាយ, ចូរនាងប្រាប់បង តើមានបំណងទៅលើអ្វី?"

ព្រះនាងទ្រង់លើកព្រះហស្តបង្អិលចុះឡើងយ៉ាងល្វន់ល្វាសដូចជា ជនវត្ត (crème) បង្ហាញព្រះមហាក្សត្រឲ្យទតច្បាស់នូវខ្សែដៃមាស ដាំពេជ្រទាំងគ្រាប់ ហើយទូលតប ព្រះឱង្ការព្រះមហាក្សត្រវិញថា៖

ត្បូងពេជ្រនេះ ពោលស្អាតបម៉ិនសូវភ្លឺ, ពណ៌សំបុរមិនសូវស្រស់ធ្វើឲ្យដៃខ្ញុំម្ចាស់ដូចជាទទេ, ឥតមានប្រដាប់អ្វីឡើយ ។ សូមព្រះអង្គទ្រង់ព្រះមេត្តាប្រោស, ធ្វើខ្ញុំម្ចាស់នូវខ្សែមាសប្រាំបត្តូ មានដាំត្បូងទទឹមក្រហម, ពណ៌ដូចឈាម ខ្ញុំម្ចាស់នឹងបានពាក់តាមបំណង, សូមទ្រង់ជ្រាប ។

ព្រះមហាក្សត្រមានព្រះបន្ទូលថា ល្អហើយនាង, បងមានដំណើរទៅឯប្រទេសត្បូងទទឹមហើយ បងនឹងយកខ្សែដៃមាសដាំត្បូងទទឹមមកឲ្យនាង ។

ព្រះអគ្គមហេសីទ្រង់យកព្រះបាទាដ៏តូចល្វន់គោះទុប៉ុះ(១) ឲ្យឮសូរហើយក្រាបទូលព្រះមហាក្សត្រថា៖ "ខ្ញុំម្ចាស់មិនពេញចិត្តនឹងសូរសៀងនៃកងជើងខ្ញុំម្ចាស់ឡើយ ។ បើទ្រង់យកទុប៉ុះជាប់ត្បូងធ្វើពីមាស, ពណ៌ក្រហមដូចភ្លើង, ខ្ញុំម្ចាស់នឹងពាក់តាមបំណង ។

ព្រះមហាក្សត្រទ្រង់មានបន្ទូលតបព្រះនាងថា៖ "បងនឹងទៅដល់ប្រទេសមាស, បងយកទុប៉ុះមាសមកពាក់កជើងឲ្យនាងទៀត" ។

ព្រះអគ្គមហេសីទ្រង់ទតខ្សែសុវណ្ណគជខ្ចង់នៅពទ្ធជុំវិញសុវណ្ណព្រះនាងដែលមានពណ៌លឿងទុំ ហើយ -

(១) ទុប៉ុះជានស័យជាកងមាសគ្រាក់ពាក់កជើង; មានចង្កឹងតូចៗគ្រឿនឡើងមានសព្ទស្ទូវពិរោះត្រូវនឹងចង្វាក់ជើងរាំនាងនាដិកាហើយត្រូវនឹងចលនានៃស្ត្រីដែលត្រាច់ទៅក្នុងសេនានាហ៍ (បន្ទប់ស្ត្រី) ។

ក្រាបទូលព្រះមហាក្សត្រថា:

"ព្រះអង្គទ្រង់ជ្រាបស្រាប់ហើយ, ត្បូងនេះ តូចណាស់ ។ មានប្រទេសខ្លះមានត្បូងធំដូចជាពង ព្រាប ។ សូមព្រះអង្គយកត្បូងបែបនោះមកឲ្យខ្ញុំ ម្ចាស់ផង" ។

ព្រះមហាក្សត្រទ្រង់មានព្រះបន្ទូលថា: នៅកណ្ដាលសាគរធំ, មានប្រទេសត្បូង, បងនឹង យកត្បូងនៃប្រទេសនោះមកឲ្យនាង, នាងនៅមាន បំណងទៅលើវត្ថុអ្វីទៀត? ។

នាង សុខកនិ ជាព្រះរាជសំណប់ឯកទ្រង់ លើកជាយសំពត់សារីមាសដែលធ្លាក់ទៅលើព្រះបាទ មាស (១) ព្រះនាងហើយទូលថា:

"សូមព្រះករុណាថ្លៃវិសេសជ្រាប! នេះមិនមែន សំពត់សារីសម្រាប់ស្លៀកទេ គឺជាវត្ថុអ្វីមួយដែលមាន ទម្ងន់ពន់ប្រមាណ ខ្ញុំម្ចាស់មិនអាចទទួល...បើសិនណា ជាខ្ញុំម្ចាស់បានសំពត់សារីពណ៌ផ្ទៃមេឃដូចជា អក្ខា- កាសដ៏ស្រាលដែលប្រៀបដូចជាកាកអាប់យក ហ៎យោ (២) មកត្បាញ ហោលរស្មីដូចជាគង្គា នោះខ្ញុំម្ចាស់គង់នឹងមាន ជីវិតតទៅដើម្បីទីងប្រដាប់តែសំពត់សារីបែបនេះ ។

ព្រះមហាក្សត្រតបថា: គួរឲ្យអនិច្ចាដល់ព្រះនាងណាស់ វិចារណញ្ញាណរបស់ព្រះនាងពេញជាគ្រប់គ្រាន់ដោយ លក្ខណៈ បងដឹងថាសំពត់សារីមាសនេះធ្វើឲ្យរលាត់ ជើងមាសនាង; មិនតែប៉ុណ្ណោះ ថែមទាំងក្ដិចក្រៀបកា- យនាងដែលទន់ល្អ ដូចជាជនវគ្គ (Crème) ។ បងទៅ! បងទៅរកឲ្យនាងនូវត្បូងទៀវមរកត សំពត់សារីផ្ទៃ មេឃដូចជាអាកាស កន្ទិតាយរផ្សរហើយក្នុងបាំងដូចជា រស្មីនៃព្រះសូរ្យបាំងលើគង្គា ។ ឱព្រះនាង, កុំឲ្យបង ចាកចេញពីនេះទៅ ដោយមិនទាន់បានឃើញភក្ត្រ នាងញញឹមស្រស់ឡើយ ។

ព្រះនាងទ្រង់ក្រឡេកញញឹមទៅព្រះមហាក្សត្រ ហើយថ្វាយបង្គំលា ។

## បញ្ចតន្ត្រៈ

(តពីលេខ ១ មក)

### កថាទី ១០

### រឿងថៃទឹងសន្តើច

ក្នុងព្រៃសាខានៃព្រះរាជាមួយព្រះអង្គ មានថែន សយនាជាទីមនោរម្យ មានថៃមួយឈ្មោះមន្ទិរសប៉ីណកី

---

១ ពាក្យថា មាស ប្រើនយកមកប្រើក្នុងរឿងព្រេងនេះ, គឺល័ក្ខណៈមានសម្បុរភ្លឺវិសេស ! ន័យថា "មាស" ជាភាសាធ្លាប់ប្រើខាងជាតិបីក្ដាលី ថា សុភា នៃលសម្រាប់ប្រើចំពោះអ្វីប្រកបដោយសុខ្ចរិយភាពប្លែក ។ ស្អាប្ប, ល្អគល្ល. អវិយវៈមាស ៖ មុខមាស, ប្រទេសមាស, មិត្តមាស....

(២) សំពត់ស្បៃនៃប្រទេសពែរ្សមានសាច់ល្អិតហ្មត់ដូចជាយកកាយោមកត្បាញ ។ បាវ្ត-ហាណា (Baft - Hana) ការយោតម្បាញ ព្រោះសំពត់ស្បៃនេះហើយហ្មត់ដូចជាពពកស្រាល បើមានស្ត្រីណាបត់ក្រយមាយស្លិតនៅពីលើម៉ែត្រលើធ្វើឲ្យសំពត់នោះហើរដោយមិនដឹងខ្លួន ។ អប្រាណាន់ (Abranan) ទឹកហូរបើស្ត្រីទូតទឹកបណ្ដោយឲ្យស្បៃនោះអណ្ដែតទឹក ស្បៃនោះទៅជាមើលមិនឃើញ ។ សាស-ណាំ (Shah -Nam) ទឹកសន្សើម ពេលសាយណ្ហសម័យបើមានស្ត្រីក្រមុំដើរលេង ពេលសាយណ្ហសម័យធ្វើឲ្យក្រពះស្បៃនោះលើស្មៅទទឹកស្បៃនោះរលាយសាច់ជួយនឹងទឹកសន្សើម ។

អាស្រ័យនៅក្នុងសន្ទាប់ កំពលពួកនៃទេនសយនា នោះ ។ ថៃនោះ តែងដញ្ញុកស៊ីព្រះលោហិតនៃព្រះភជាដោយក្តីរីករាយ ។ ថ្ងៃមួយ មានសង្កើចមួយឈ្មោះអគ្គិមុខ ក៏ចូលទៅកាន់កំពលនៃទេនសយនានោះដែរ ។ ថៃឃើញសង្កើច ហើយមានចិត្តព្រួយបារម្ភក្រាំង ទើបសួរទៅថា: "នែសង្កើច! ហេតុអ្វីក៏បានជាចូលមកនៅទីនេះ? ទីនេះឯងមិនត្រូវចូលមកទេ ចេញឲ្យឆាប់ ៗ ទៅ! ចេញទៅកាន់គេមិនទាន់ឃើញឯងនៅទីនេះ" ។ សង្កើចឆ្លើយតបថា: ហៃ លោកមានបុណ្យអើយ ! បើទុកជាមនុស្សអាក្រក់មកដល់ផ្ទះយើងហើយ យើងក៏មិនគួរនិយាយពាក្យអសុរសយ៉ាងនេះដែរ, ព្រោះថា:-

២៥៣-ចូរមក! មកណេះ! អញ្ជើញអង្គុយលើអាសនៈនេះ? ហេតុអ្វីក៏ខានអញ្ជើញមកលេងយូរម្ល៉េះ? អ្នកសុខសប្បាយជាទេឬ ហ៊ឹ អ្នកទុព្វលណាស់តើ! សូមជូនពរអ្នកឲ្យសុខសប្បាយ! ខ្ញុំមានចិត្តរីករាយសប្បាយណាស់បានឃើញអ្នកមកលេង! នេះជាសិរីនៃលោកសប្បុរសទាំងឡាយ ដែលលោកឃើញនរជនណាមួយមកដល់ផ្ទះ បើទុកជាជននោះជាជនថោកទាបក៏ដោយ លោកតែងតែនិយាយដូច្នេះដរាប ។ នេះជាធម៌នៃម្ចាស់ផ្ទះទាំងឡាយ ជាធម៌ងាយសោះ ហើយអាចប្រគល់ស្ថានសួគ៌ឲ្យទៀតផង ។

មួយទៀត ខ្ញុំធ្លាប់បានភ្លក់ឈាមនៃជនច្រើននាក់ តែឈាមជនជាតិទាំងនោះមិនឆ្ងាញ់ពិសារសោះ ព្រោះមកពីអាហារមិនល្អ ខ្លះប្រៃ ខ្លះហិរ ខ្លះចត់ ខ្លះប្រហាក់ ខ្លះទៀតជូរល្វីង ខ្ញុំមិនដែលបានភ្លក់ឈាមឆ្ងាញ់យ៉ាងនេះសោះ បើលោកអនុគ្រោះឲ្យខ្ញុំបានរីករាយផង ខ្ញុំនឹងបានសប្បាយដោយបានភ្លក់ឈាមនៃព្រះភជាអង្គនេះ ដែលផ្សំមកពីអាហារមានគ្រឿងទេសគ្រប់មុខសុទ្ធសឹងវិសេស ព្រមទាំងគ្រឿងផ្អែមផ្សេងៗទាំងឡាយផង ព្រោះថា÷

២៥៤-បំណាញ់អណ្តាតនៃជនត្រិត្រក្ត នៃព្រះភជាក្តីលោកពោលថា ដូចៗគ្នាទេ ព្រោះតែបំណាញ់អណ្តាតនេះ តែម្យ៉ាងជា សារៈសំខាន់បានជាជនាទុជនទាំងឡាយប្រឹងប្រែងរកទ្រព្យ ។

២៥៥-នៅក្នុងលោកនេះ ថាបើមិនមានអំពើណាមួយដែលធ្វើឲ្យរីករាយអណ្តាតទេ ទុះប្រាកដជាមិនមានខ្ញុំបំរើទេ ទុះប្រាកដជាមិនមានជនណានៅក្នុងអំណាចនៃជនណាមួយទេ ។

២៥៦-មនុស្សនិយាយពាក្យមិនពិត សេពគប់ជនណាដែលខ្លួនមិនត្រូវសេពគប់ ឬក៏ចេញចាកប្រទេសខ្លួនទៅប្រទេសក្រៅ ។ ទាំងអស់នេះក៏ព្រោះតែពោះខ្លួនប៉ុណ្ណោះ ។

ដូច្នេះហើយបានជាខ្ញុំចូលមកសូមជ្រកអាស្រ័យនៅក្នុងផ្ទះលោក សូមអាហារលោកបរិភោគ ព្រោះតែមានសេចក្តីស្រេកឃ្លាន មិនសមគួរបើលោកបរិភោគឈាមនៃព្រះភជាដ៏ឆ្ងាញ់នេះតែម្នាក់ឯងសោះ ។

(នៅមានត)



# ប្រវត្តិនៃក្មេងកំព្រា

(តពីលេខ ១ មក)

បំផុតរបស់កុមារសំណាងនេះគ្រាន់តែចេញផុតទៅអ្នកពួកឃាតមកដល់ភូមិ ដល់ពេលសំណាងត្រឡប់មកផ្ទះវិញ ក៏ឃើញតែផេះទីងរងើកភ្លើងនៅទីផ្ទះរបស់អ្នក ដូចជាជនអ្នកសែនសពឪពុករបស់អ្នកដែរ; ក្នុងគ្រានោះអ្នកមិនបានទីដេកទេ គឺអ្នកឡើងលើដើមស្វាយមួយអង្គុយលើបង្អៀចមែកមើលផ្ទះឪពុករបស់អ្នក, ពេលដែលកំពុងអង្គុយដូចនេះស្រាប់តែឃើញជនអ្នកសែនសពឪពុកខ្លួនដើរចូលមក អ្នកឃើញដូចនោះក៏ចុះចាកដើមស្វាយភ្លាមដោយប្រាថ្នានឹងរត់ចេញ ទទួលជនទាំងនោះដេញចាប់ទាន់ ហើយនាំទៅបង្ហាញរូបបុគ្គលស្លាប់; កុមារក៏សត់កាលបើជួបប្រទះហេតុដ៏វិប្តកនេះ អ្នកពុំអាចយល់បានថាឪពុកអ្នកជាអ្វីបានឡើយ អ្នកស្ទុះចិបយ៉ាងស្វិត ជនទាំងឡាយក៏ស៊ើរតែប្រឡេះកុមារចេញពីសពមិនបាន ។

ខ្ញុំសូមសួរថាតើពេលនោះមានជនណាអាចសងសឹកជំនួសសពបានចំពោះអធម្មកម្មនេះទេ ? ។ មាន! តែជនទាំងឡាយខ្លាចកំហុសជាងយកខ្លួនទៅប្តូរ ដោយមិនដឹងហេតុ គ្រាន់តែកើតសេចក្តីសង្វេគថាខ្មែរពេលនេះស្លាប់ដូចជាសត្វតិរច្ឆាន ។

ជនទាំងឡាយក៏បបួលគ្នាជីកដីកប់សពក្នុងពេលនោះភ្លាមនៅលើទីភូមិភ្លើងឆេះនោះ, សំណាងក៏ត្រូវជនទាំងឡាយលួងលោមឲ្យទៅជាមួយនឹងគេទៅ ។

កុមារសំណាងត្រូវបានមកនៅអាស្រ័យជាមួយនឹងតាសំដែលជាអ្នកចិញ្ចឹមសត្វពាហនៈ នៅក្នុងឃុំកូនសត្វ ស្រុកកំពត ខេត្តកំពត; សំណាងតែងតែឃ្វាលសត្វពាហនៈឲ្យតាសំជារាល់ថ្ងៃពុំដែលខាន; តែជារាល់ថ្ងៃអ្នកតែងនាំគោក្របីមកឃ្វាលនៅទីជិតផ្នូរឪពុករបស់អ្នក, ពេលដែលអ្នកមកដល់ផ្នូរឪពុកអ្នកហើយអ្នកដកស្មៅបេះផ្កាឈើព្រៃមកដោតជាលំអនៅលើផ្នូរអាការយ៉ាងនេះកុមារធ្វើអស់ពេលជាពីរឆ្នាំគត់ ។ អ្នកមានជីវភាពជាសុខក្នុងឋានៈជានាយគង្វាលពាហនៈលុះដល់អាយុរបស់អ្នកបាន ១០ ឆ្នាំ ។

នៅខាងលិចភូមិចាស់នៃកុមារសំណាងមានភូមិមួយឈ្មោះមហាវ៉ន ទីនោះមានជនអ្នកស្រុកស្លូតប្រហែលជាដប់ត្រកូល សុទ្ធតែជាខ្មែរជាតិអ្នកកាន់ព្រះពុទ្ធសាសនាដោយមុតមាំ; មានអ្នកប្រាជ្ញសាសនាជាច្រើនអង្គក្នុងពជដាទី និមន្តទៅផ្សាយសាសនានៅទីនោះជាញឹកញយ; ភូមិនោះទុកជាដំបន់មួយដែលមាន

(នៅមានត)

## សូមលោកអ្នកអានទាំងឡាយដាក់ឈ្មោះមនុស្សទាំង ១៤ ពួកនេះ

១- មនុស្សខ្លះមិនសូវចេះស្តីនិយាយទេ ប៉ុន្តែមានគំនិតល្អ, ធ្វើតែអំពើល្អ, មានព្យាយាមមុតមាំ;

២- មនុស្សខ្លះនិយាយច្រើន ប៉ុន្តែធ្វើអ្វីមិនសម្រេចដូចមាត់ថា ;

៣- មនុស្សខ្លះជាអ្នកនិយាយគួរដល់ការ គឺនិយាយស្តីមិនឲ្យលើសខ្វះ មាត់ថាយ៉ាងណាការងារយ៉ាងនោះ ,

៤- មនុស្សខ្លះគិតត្រឹមតែខ្លួន តាមតែអ្នកណាដូចម្តេចក៏ដោយ ;

៥- មនុស្សខ្លះប្រឹងបំពេញប្រយោជន៍ដល់អ្នកដទៃ ព្រោះសង្ឃឹមឃើញថាគេនឹងផ្តល់ប្រយោជន៍ដល់ខ្លួនវិញ បើមិនដូចបំណងនឹងគាក់អន់ចិត្តយ៉ាងខ្លាំង ;

៦- មនុស្សខ្លះ ទំនុកបំរុងគេមិនសំគាល់ប្រយោជន៍ពីគេវិញប៉ុន្មាន បានក៏យកមិនបានក៏ហើ ;

៧- មនុស្សខ្លះប្រឹងបំពេញទាំងប្រយោជន៍ខ្លួនទាំងប្រយោជន៍អ្នកដទៃ ;

៨- មនុស្សខ្លះចិត្តល្អពន់ពេក, មានចិត្តករុណាករុណាសូវច្រើន, ស៊ូរងទុក្ខវេទនាខ្លួនឯងឲ្យតែអ្នកដទៃបានសុខស្រួល ;

៩- មនុស្សខ្លះប្រឹងយកចិត្តទុកដាក់បំពេញប្រយោជន៍ឲ្យប្រទេសជាតិឲ្យបានចំរើនរុងរឿង ;

១០- មនុស្សខ្លះគិតតែពីបៀតបៀនបំផ្លាញអ្នកដទៃ ក្រសោបយកប្រយោជន៍មកដាក់លើខ្លួន គ្មានសេចក្តីអៀនខ្មាស ឥតក្រែងប្រណី ;

១១- មនុស្សខ្លះបំផ្លាញឲ្យគេវិនាស ហើយឥតមានប្រយោជន៍អ្វីប៉ុនសក់ដល់ខ្លួន បានតែបាបកាលបើនឹកឡើងដឹងខ្លួនឯងថាជាមនុស្សអាក្រក់ដោយពិត ;

១២- មនុស្សខ្លះខ្ជិលធ្វើការ ដើរអែបអបដោយសារគេ រស់បានអាស្រ័យគេឲ្យ, ប្រព្រឹត្តតែអំពើឥតប្រយោជន៍ ;

១៣- មនុស្សខ្លះជាសត្រូវចំពោះការមានប្រយោជន៍ក្នុងប្រទេសជាតិ ;

១៤- មនុស្សខ្លះជាអ្នកមានការងារគួរសម តែគ្មានគំនិត តាមតែគេដឹកដូចសត្វ ល្អក៏អីអាក្រក់ក៏អើ !



ព្រះតេជ-ព្រះគុណ ពោធិវង្ស ចាន់ហ្វាន់ សាលាបាលីជាន់ខ្ពស់ និងព្រះអរិយកស្សប ប្រតិភូសម្តេចព្រះសុធម្មាធិបតីនិមន្តជាអធិបតីក្នុងពិធីប្រជុំពោលប្រាស្រ័យ រវាងសិស្សចាស់នឹងក្រុមមិត្តសាលាបាលីទាំងឡាយ ។



ក្រុមសិស្សចាស់នឹងមិត្តសាលាបាលីទាំងឡាយដែលបានមកប្រជុំក្នុង ៩% ក្នុងពិធីពោលប្រាស្រ័យរវាងសិស្សចាស់ នឹងមិត្ត ដោយមានព្រះសង្ឃជាច្រើន និមន្តទៅក្នុងពិធីនេះផង កាលពីថ្ងៃ ទី ៦ កុម្ភៈ ឆ្នាំ ១៩៥៤ នៅវត្តលង្កា ភ្នំពេញ ។

សូមបបួលអស់លោក - អ្នកស្ម័គ្រចិត្ត អញ្ជើញទៅកំសាន្តនគរវត្ត !

មុននឹងអញ្ជើញទៅខ្ញុំសូមផ្តាំថា:

កាលបើអស់លោកអ្នកទៅដល់នគរវត្ត ហើយមុខជានឹងជួបខ្ញុំ នៅរាជធានីភ្នំពេញ; បើអញ្ជើញត្រឡប់មកកាន់រាជធានីវិញ នោះនឹងបានចាប់ដៃខ្ញុំ នៅនគរវត្ត ។

ចុះទីណា ដែលលោក-អ្នកនឹងខ្ញុំត្រូវជួបគ្នា?

សូមឆ្លើយតាមលិខិត !

រោងពុម្ព តាក លេខ ០១១ វិថីព្រៃនគរភ្នំពេញ